# ពុទ្ធប្បវត្តិ

ភាគ ២

## អភិនិក្ខមនកថា

សម្រាប់សាលាធម្មវិន័យ

*រៀបរៀងដោយ*

គណៈកម្មការធម្មវិន័យ

ធម្មវិនយោ លោកេ បវត្តតុ !

ចម្លងដោយ ភិក្ខុ ជួន សុចិត្ត

ព.ស ២៥៥៦

កំណោយពីលោក ឈ្មោះ ឃុន សំរ៉ង ក្រុងតាខ្មៅ សើរៀប
តំកល់ក្នុង elibrary of Cambodia កក្កដា 2015

# ពុទ្ធប្បវត្តិ

## ភាគ ២

## អវិទូរេនិទាន

សម្រាប់សាលាធម្មវិន័យ

*រៀបរៀងដោយ*

គណៈកម្មការធម្មវិន័យ

ធម្មវិនយោ លោកេ បវត្តតុ ।

ចម្លងដោយ ភិក្ខុ ជួន សុចិត្ត

ព.ស ២៥៥៦

## អារម្ភកថា

សៀវភៅនេះឈ្មោះ **ពុទ្ធប្បវត្តិ** ដំណាលពីប្រវត្តិ គឺដំណើរប្រព្រឹត្ត ឬពី រឿងរ៉ាវនៃព្រះពុទ្ធជាម្ចាស់ ដរាបដល់បរិនិព្វានជាទីបំផុត ។

**ពុទ្ធប្បវត្តិ** នេះ យើងជាគណៈកម្មការធម្មវិន័យ បានដកស្រង់សេចក្ដីពីក្នុងគម្ពីរឯកនិបាតជាតកខ្លះ ពីក្នុងគម្ពីរអដ្ឋកថាធម្មចក្កប្បវត្តនសូត្រខ្លះ ពីក្នុងគម្ពីរជិនមហានិទានខ្លះ ដែលមានសេចក្ដីផ្សេងគ្នាដោយអន្លើៗ មករៀបរៀងរំលែកចែកជា ៣ និទាន គឺទី ១ ដែលបានបោះពុម្ពរួចហើយហៅថា **ពុទ្ធប្បវត្តិ ទូរេនិទាន** ពណ៌នាអំពីព្រះពុទ្ធនៃយើង កាលនៅជាពោធិសត្វឈ្មោះ **សុមេធបណ្ឌិត** ដែលកើតក្នុងត្រកូលព្រាហ្មណ៍ ដរាបដល់មកកើតជាសន្តុសិតទេវបុត្រ ឋិតនៅឋានតុសិតទេវលោក។ **ទី២** ហៅថា **ពុទ្ធប្បវត្តិ អវិទូរេនិទាន** ពណ៌នាអំពីពោធិសត្វច្យុតចាកឋានតុសិតទេវលោក មកកើតជា **សិទ្ធត្ថកុមារ** ក្នុងសក្យត្រកូល ដរាបបានត្រាស់ជាព្រះពុទ្ធលើរតនបល្ល័ង្កក្រោមពោធិព្រឹក្ស ។ ទី៣ ដែលបំរុងនឹងបោះពុម្ពក្នុងកាលខាងមុខ ហៅថា **ពុទ្ធប្បវត្តិសន្តិកេនិទាន** ពណ៌នាអំពីព្រះអង្គបានត្រាស់ជាព្រះពុទ្ធហើយ ទ្រង់ស្ដេចត្រាច់ចរប្រោសសត្វ គង់នៅក្នុងទីនោះៗ ដរាបដល់ចូលនិព្វាន ។

**ពុទ្ធប្បវត្តិ អវិទូរេនិទាន** នេះ វេលាដែលគណៈកម្មការធម្មវិន័យបានរៀបរៀងចប់ហើយ នាំយកទៅប្រគេនសម្ដេចសង្ឃនាយកជាប្រធាននៃគណៈកម្មការធម្មវិន័យ. សម្ដេចទទួលផ្ទៀងផ្ទាត់ពិនិត្យកែសំរួល យល់ឃើញថា ត្រឹមត្រូវ ល្មមដល់ការសិក្សាក្នុងសាលាធម្មវិន័យទូទៅក្នុងកម្ពុជរដ្ឋ ។

សូមឱ្យការសិក្សាធម្មវិន័យរបស់សិក្ខាកាមកុលបុត្រទាំងឡាយ ដល់នូវការលូតលាស់ចំរើនជាភិយ្យោភាព អស់កាលជានិច្ចនិរន្តរ៍តទៅ !

**គណៈកម្មការធម្មវិន័យ**

# ពុទ្ធប្បវត្តិ

## អវិទូរេនិទាន

## ១. បញ្ចមហាវិលោកនកថា

កាលដែលព្រះបរមពោធិសត្វ កំពុងគង់នៅក្នុងតុសិតបុរី ឋានទេវលោក. មានពុទ្ធកោលាហល[១] កើតឡើង គឺមានពួកលោកបាលទេវតា (ទេវតាអ្នករក្សាលោក) ហោះចុះមកឃោសនាប្រកាសប្រាប់ដល់មនុស្សលោកថា "ម្នាលអ្នកនិទ្ទុក្ខទាំងឡាយអើយ ! អំណើះកាលកន្លងពីត្រឹមនេះទៅ នៅចំនួន១០០០ឆ្នាំទៀត នឹងមានព្រះពុទ្ធបានត្រាស់ក្នុងលោក" ។ ពួកទេវតាដែលឋិតនៅក្នុងចក្កវាឡទាំងមួយម៉ឺនលោកធាតុ បានឮពុទ្ធកោលាហលនោះហើយ ក៏មានចិត្តរីករាយទាំងអស់គ្នា ។ លុះដល់កាលកំណត់ជន្មាយុបួនពាន់ឆ្នាំទិព្វក្នុងឋានតុសិត (៥៧ កោដិ ៦ លានឆ្នាំមនុស្ស) នៃព្រះបរមពោធិសត្វ. ពួកទេវតាទាំងនោះក៏ប្រជុំគ្នា ចូលទៅអារាធនាព្រះបរមពោធិសត្វដោយពាក្យថា "បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ! បារមីទាំង១០ ដែលព្រះអង្គបានកសាងបំពេញមក

---

(១) *ពុទ្ធកោលាហល* (គឺការផ្អើលជ្រួលជ្រើមព្រោះឮថា ព្រះពុទ្ធនឹងបានកើតឡើង) ។ *កោលាហល* មាន ៣ យ៉ាងគឺ: ១-*កប្បកោលាហល* មានពួកកាមាវចរទេវតាឈ្មោះលោកព្យូហៈ ស្លៀកពាក់សំពត់ពណ៌ក្រហម រំសាយសក់ យកដៃជូតទឹកភ្នែក ត្រាច់មកប្រកាសប្រាប់ដល់មនុស្សទាំងឡាយក្នុងលោកថា ម្នាលអ្នកនិទ្ទុក្ខទាំងឡាយអើយ ! អំណើះកាលកន្លងពីត្រឹមនេះទៅនៅចំនួន ១សែនឆ្នាំទៀត លោកនេះក្តី មហាសមុទ្រក្តី មហាប្រឹថពីនេះក្តី ស្តេចភ្នំឈ្មោះសិនេរុក្តី នឹងវិនាសដោយភ្លើងប្រល័យកប្ប. ហេតុនោះ អ្នកទាំងឡាយចូរចំរើននូវព្រហ្មវិហារ គឺមេត្តា ករុណា មុទិតា ឧបេក្ខា. ចូរបំរើមាតាបិតាជាដើម ។ ២-*ពុទ្ធកោលាហល* (មានសេចក្តីអធិប្បាយក្នុងសៀវភៅនេះហើយ) ។ ៣-*ចក្កវត្តិកោលាហល* មានពួកទេវតាត្រាច់មកឃោសនាប្រកាសប្រាប់ ដល់មនុស្សលោកថា ម្នាលអ្នកនិទ្ទុក្ខទាំងឡាយអើយ ! អំណើះកាលកន្លងពីត្រឹមនេះទៅនៅ ១០០ឆ្នាំទៀត នឹងមានស្តេចចក្រពត្តិកើតឡើងក្នុងលោក ។ល ។

អស់កាលជាយូរអង្វែងហើយនោះ មិនមែនព្រោះប្រាថ្នាសក្កសម្បត្តិ, មារ-សម្បត្តិ, ចក្កវត្តិសម្បត្តិ ឬព្រហ្មសម្បត្តិទេ, ដែលព្រះអង្គបំពេញមក ព្រោះប្រាថ្នាចំពោះតែសព្វញ្ញុតញ្ញាណតែមួយយ៉ាងប៉ុណ្ណោះ, កាលនេះ ជាកាលគួរដល់ព្រះអង្គហើយ, សូមព្រះអង្គច្យុតទៅកើតក្នុងមនុស្សលោក ដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធចម្លងសត្វលោកឱ្យរួចផុតចាកវដ្តសង្សារ ។ គ្រានោះ ព្រះបរមពោធិសត្វមុននឹងទទួលពាក្យប្ដេជ្ញារបស់ទេវតាទាំងឡាយ, ទ្រង់ប្រមើលមើលនូវមហាវិលោកនៈទាំង ៥ ប្រការ គឺកាល ១ ទ្វីប ១ ប្រទេស ១ ត្រកូល ១ មាតា ១ ។

ប្រមើលមើលនូវកាលនោះ គឺប្រមើលមើលឱ្យដឹងច្បាស់ថា កាលណាបើសត្វមានអាយុចំរើនលើសពីមួយសែនឆ្នាំទៅ កាលនោះ ឈ្មោះថា កាលមិនគួរព្រះពុទ្ធមកកើតទេ, ព្រោះសត្វទាំងឡាយមិនប្រាកដដោយជាតិ ជរា និងមរណៈ ដ្បិតធម្មទេសនារបស់ព្រះពុទ្ធ មិនផុតចាកត្រៃលក្ខណ៍ឡើយ, សត្វទាំងឡាយមុខជាមិនសំគាល់នូវធម៌ដែលគួរស្ដាប់គួរជឿ, ហេតុនោះ ការត្រាស់ដឹងនូវមគ្គ និងផល ក៏មិនមានដល់ពពួកសត្វ, ម្ល៉ោះហើយសាសនៈ គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ក៏នឹងក្លាយទៅជាមិនមែនជានិយ្យានិក-ធម៌ ឬកាលណាសត្វមានអាយុថយតិចចុះពី ១០០ ឆ្នាំមក កាលនោះ ឈ្មោះថា កាលដែលព្រះពុទ្ធមិនគួរមកកើតដែរ ព្រោះសត្វទាំងឡាយមានកិលេសក្រាស់ក្នុងសន្ដាន បើទុកជាព្រះពុទ្ធប្រទានឱវាទ ដល់សត្វដែលក្រាស់ដោយកិលេសដូច្នោះ ឱវាទនោះឯង រមែងវិនាសបាត់ទៅយ៉ាងឆាប់, លុះតែកាលណា សត្វមានអាយុក្ដីយ៉ាងច្រើនត្រឹម ១ សែនឆ្នាំ យ៉ាងតិចត្រឹម ១០០ ឆ្នាំ កាលនោះ ទើបឈ្មោះថា ជាកាលគួរដល់ព្រះពុទ្ធកើតឡើងក្នុងលោក ។

ប្រមើលមើលនូវទ្វីបនោះ គឺ ប្រមើលមើលនូវទ្វីបដែលព្រះពុទ្ធតែងកើត, ព្រោះថា អតីតពុទ្ធទាំងឡាយ មិនដែលកើតក្នុងទ្វីប ៣ គឺបុព្វវិទេហទ្វីប, អមរគោយានទ្វីប និងឧត្តរកុរុទ្វីបទេ, ទ្រង់កើតតែក្នុងជម្ពូទ្វីបប៉ុណ្ណោះ ។

ប្រមើលមើលនូវប្រទេសនោះ គឺ ប្រមើលមើលនូវប្រទេសដែលព្រះពុទ្ធតែងកើត ព្រោះថា ព្រះពុទ្ធទាំងឡាយក្តី ព្រះបច្ចេកពុទ្ធទាំងឡាយក្តី អគ្គសាវ័កទាំងឡាយក្តី ស្តេចចក្រពត្តិក្តី ក្សត្រ-ព្រាហ្មណ៍-គហបតិមហាសាលទាំងឡាយជាអ្នកមានស័ក្តិធំៗក្តី មិនដែលកើតក្នុងបច្ចន្តប្រទេសទេ កើតតែក្នុងមជ្ឈិមប្រទេស[(១)] ប៉ុណ្ណោះ ។

ប្រមើលមើលនូវត្រកូលនោះ គឺប្រមើលមើលត្រកូលដែលគួរចុះមកកើត ព្រោះថា ព្រះពុទ្ធទាំងឡាយ មិនដែលកើតក្នុងវេស្សត្រកូល និងសុទ្ទត្រកូលទេ, ទ្រង់កើតតែក្នុងត្រកូលពីរ គឺ ខត្តិយត្រកូល និងព្រាហ្មណត្រកូល ត្រកូលណាមួយ ។

ប្រមើលមើលនូវមាតានោះ គឺប្រមើលមើលនូវមាតាដែលគួរចាប់កំណើត ព្រោះថា ស្ត្រីជាពុទ្ធមាតា ជាអ្នកមិនឡេះឡោះដោយបុរសក្នុងកាមគុណ, ជាអ្នកមិនសេពសុរាជាដើម, ជាអ្នកមានអភិនិហារបានកសាងទុកមកអំពីអតីតជាតិ ព្រមទាំងមានបារមីបានបំពេញមកអស់ ១សែនកប្ប, ជាអ្នកជាប់សីល ៥ ជានិច្ចតាំងអំពីកំណើតមកផង, ជាអ្នកប្រកបដោយសេចក្តីសុខជាប្រក្រតី មិនមានរោគណាមួយចូលមកបៀតបៀនបានផង, វេលាព្រះបរមពោធិសត្វប្រសូតមក ពុទ្ធមាតាមានព្រះជន្មតាំងនៅបានតែត្រឹម ៧ ថ្ងៃផង ។

លុះព្រះពោធិសត្វប្រមើលមើលនូវមហាវិលោកនៈទាំង ៥ ឃើញថា

(១) មជ្ឈិមប្រទេសនេះឯង ដែលហៅថា *ជម្ពូទ្វីប* គឺប្រទេសឥណ្ឌាសព្វថ្ងៃនេះ ។

មានបរិបូណ៌គ្រប់គ្រាន់គួរដល់ព្រះអង្គហើយ ទើបបានទទួលពាក្យប្តេជ្ញារបស់ទេវតាទាំងឡាយ ថានឹងចុះមកកើតក្នុងមនុស្សលោក តាមសេចក្តីអារាធនារបស់ទេវតាទាំងឡាយនោះ ។

ចប់មហាវិលោកនកថា

## ២.គព្ភោក្កន្តិកថា

កាលដែលព្រះបរមពោធិសត្វ បានប្រមើលមើលនូវមហាវិលោកនៈទាំង ៥ រួចហើយ ទើបចូលទៅកាន់នន្ទវ័នឧទ្យាន ដែលឋិតនៅក្នុងតុសិតបុរីជាមួយនឹងពួកទេវតាជាបរិវារ ទ្រង់រលឹកនូវបុព្វេកតកុសលកម្មដែលបានកសាងទុកមកជាអនេកជាតិ ហើយច្យុតចាកតុសិតទេវលោក មកចាប់បដិសន្ធិក្នុងផ្ទៃនៃព្រះនាង **មាយាទេវី** ក្នុង **សាក្យត្រកូល** ក្នុងថ្ងៃ **ព្រហស្បតិ៍ ១៥កើត** ខែ**អាសាឍ** **ឆ្នាំរកា** សឹងប្រកបដោយហេតុអស្ចារ្យផ្សេងៗ ។

ក្នុងរវាងកាលមុន ៧ ថ្ងៃ អំពីថ្ងៃពេញបូណ៌មីនៃខែអាសាឍ. ពួកមហាជនដែលនៅក្នុងក្រុងកបិលពស្តុ[១] នាំគ្នាលេងមហោស្រព ។ ចំណែកខាងព្រះនាងមាយាទេវី ក៏បានស្អិតស្អាងព្រះកាយដោយផ្កាកម្រង និងគ្រឿងក្រអូបផ្សេងៗហើយទ្រង់ក្រសាលនក្ខត្តឫក្សអស់ ៧ ថ្ងៃ. លុះដល់ថ្ងៃទី ៧ គឺជាថ្ងៃពេញបូណ៌មីខែអាសាឍ. វេលាព្រឹកឡើង ព្រះនាងតើនឡើងអំពីព្រលឹម ទ្រង់ស្រង់សុគន្ធវារីស្រេចហើយ ក៏បរិច្ចាគទ្រព្យចំនួន ៤ សែនកហាបណៈឱ្យជាទានព្រះនាងទ្រង់សោយនូវភោជនរួចហើយ ក៏អធិដ្ឋាននូវអង្គនៃឧបោសថសីល

(១) បាលីថា *កបិលវត្ថុ*. សំស្ក្រឹតថា *កបិលវស្តុ*. ផ្លាស់ "វ" ជា "ព" ជា *កបិលពស្តុ* ហៅក្លាយមកទៀតថា *កបិលភស្តុ* ។

ហើយឡើងផ្ទំលើក្រឡាព្រះបន្ទំដ៏មានសិរី ។

លុះដល់បច្ចូសសម័យ ព្រះនាងកំពុងផ្ទំស្កប់ស៊ប់ បានឃើញសុបិនថា មានចាតុម្មហារាជទាំង ៤ មកលើកព្រះនាងទាំងសិរីសយនា នាំចូលទៅកាន់ព្រៃហេមពាន្ត ហើយដាក់ដឹកល់លើមនោសិលាមានទំហំប្រមាណ ៦០យោជន៍ ខាងក្រោមមហាសាលព្រឹក្ស[១] មួយដើមកំពស់ ៧យោជន៍[២] ។ គ្រានោះ នាងទេពធីតាទាំងឡាយរបស់ចាតុម្មហារាជទាំង ៤ នោះ មកអញ្ជើញព្រះនាងទៅស្រង់ទឹក នៅនាស្រះអនោតត្ត ដុសជំរះព្រះកាយហើយអញ្ជើញព្រះនាងឱ្យទ្រង់សំពត់ទិព្វ ហើយលាបដោយគ្រឿងក្រអូបទិព្វ ។ ក្នុងទីជិតស្រះនោះ មានរជតបពិត (ភ្នំប្រាក់) មួយ មានសុវណ្ណវិមានមួយឋិតនៅលើរជតបពិតនោះ ។ នាងទេពធីតាទាំងឡាយតាក់តែងទិព្វសយនារួចហើយ ក៏អញ្ជើញព្រះនាងឱ្យទៅផ្ទំក្នុងសុវណ្ណវិមាននោះ បែរព្រះសិរទៅទិសខាងកើត ។ ក្នុងទីជិតរជតបពិតនោះ មានសុវណ្ណបពិត (ភ្នំមាស) មួយ មានសេតហត្ថី (ដំរីស) មួយត្រាច់ចរលើសុវណ្ណបពិតនោះ ហើយចុះមក ឡើងលើរជតបពិត ។ សេតហត្ថីនោះ មានប្រមោយកាន់សេតបទុម (ផ្កាឈូកស) បន្លឺនូវកោញ្ចនាទ ចូលមកក្នុងសុវណ្ណវិមាន ដើរប្រទក្សិណព្រះនាង ៣ ជុំ ហើយហាក់ដូចជាទម្លាយព្រះ

(១) សាលព្រឹក្សយើងធ្លាប់យល់យូរមកហើយថា "ដើមរាំងភ្នំ" តាមពិតមិនមែនរាំងភ្នំទេ ជាឈ្មោះឈើមួយប្រភេទមានស្លឹកស្តើងរាងស្រួចជ្រលមវែង១ មានទ្រនុង ជាឈើធំមានម្លប់ល្អ មានផ្កាធំ១ ទងវែង១ចេញពីដើម មានសម្បុរស្រដៀងនឹងផ្កាឈូកក្រហម មានក្លិនក្រអូបឈ្ងុយ ផ្លែ ស្រដៀងនឹងផ្លែក្រពៅ ប៉ុន្តែធំជាងផ្លែក្រពៅបន្តិច ។ល។ ក្នុងអភិធានប្បទីបិកានិងអដ្ឋកថាច្រើនអធិប្បាយថា សាល-ព្រឹក្សនេះ ហៅថា អស្សកណ្ណព្រឹក្ស "ដើមត្រចៀកសេះ" ក៏បាន បណ្ឌិតក្នុងកម្ពុជរដ្ឋប្រែថា ដើមត្រ-ចៀកប្រើស ។ ព្រះសម្ពុទ្ធទ្រង់ប្រសូត ទ្រង់ចូលនិព្វានក្រោមដើមសាលព្រឹក្ស ឬដើមអស្សកណ្ណព្រឹក្សនេះ ។ (២) ខ្នាតវាស់កំពស់គិត ១យោជន៍ប្រវែង ៧ហត្ថ. ៧យោជន៍ត្រូវជា ៤៩ហត្ថ ។

ឧទរចូលមកតាមសីរប្រទេសខាងស្តាំ ។ សុបិននិមិត្តនេះ គឺជាតួអង្គព្រះពោធិសត្វចុះចាប់បដិសន្ធិក្នុងវេលានោះឯង ។

ក្នុងខណៈដែលព្រះបរមពោធិសត្វ ចុះចាប់បដិសន្ធិក្នុងផ្ទៃនៃព្រះមាតានោះ លោកធាតុទាំង១ម៉ឺនក៏រីកញាប់ញ័ររញ្ជួយដំណាលគ្នាទាំងអស់ ព្រមទាំងបុព្វនិមិត្ត ៣២ ប្រការ[១] មានពន្លឺភ្លឺផ្លុះទូទៅសព្វចក្រវាឡជាដើម ដើម្បីសំដែងនូវគុណ គឺសេចក្តីអស្ចារ្យធំធេងរបស់ព្រះបរមពោធិសត្វ ក៏កើតឡើងក្នុងកាលនោះឯង ។

---

១-បុព្វនិមិត្ត៣២ប្រការនោះគឺ ១-មានពន្លឺភ្លឺផ្លុះផ្សាយទៅក្នុងចក្រវាឡទាំងមួលម៉ឺន. ២-មនុស្សខ្វាក់ទៅជាមានភ្នែកភ្លឺ. ៣-មនុស្សថ្លង់ ស្តាប់សូរស័ព្ទសម្លេងបាន. ៤-មនុស្សគ អាចនិយាយឆ្លើយឆ្លងគ្នាបាន. ៥-មនុស្សគម បែរជាមានខ្លួនត្រង់វិញបាន. ៦-មនុស្សខ្វិន មានអវយវៈត្រង់ដើរបាន. ៧-សត្វដែលជាប់ចំណង ឬខ្នោះឃ្នាងជាដើម បានរួចចាកចំណង. ៨-ភ្លើងដែលឆេះនៅក្នុងឋាននរកទាំងពួង ក៏រលត់អស់. ៩-សេចក្តីស្រេកឃ្លានរបស់ពួកប្រេត ក៏បានស្ងប់រម្ងាប់. ១០-ពួកសត្វតិរច្ឆាន លែងមានសេចក្តីភិតភ័យ. ១១-រោគរបស់សត្វទាំងឡាយ ក៏បានស្ងប់រម្ងាប់. ១២-ភ្លើងកិលេស មានរាគៈជាដើមរបស់សត្វទាំងពួង ក៏បានស្ងប់. ១៣-សត្វទាំងពួងពោលពាក្យជាទីស្រឡាញ់ពេញចិត្តដល់គ្នានឹងគ្នា. ១៤-ពួកសេះ កញ្ជ្រៀវដោយសម្លេងដ៏ពីរោះ. ១៥-ពួកដំរី ស្រែកដោយសម្លេងដ៏ពីរោះ. ១៦-តូរ្យតន្ត្រីទាំងពួង ក៏បញ្ចេញសម្លេងទ្រហឹងអឺងអាប់ដោយខ្លួនឯង មិនបាច់អ្នកណាវាយដំផ្លុំគូត. ១៧-គ្រឿងអាភរណៈដែលពាក់នឹងដៃមនុស្សទាំងឡាយ ក៏បញ្ចេញសូរស័ព្ទលាន់ឮឡើង. ១៨-ទិសទាំងពួង ក៏ភ្លឺស្រឡះថ្លាស្អាត. ១៩-ខ្យល់ត្រជាក់ជាត់ត្រសៀកៗមក ឱ្យកើតសេចក្តីសុខដល់សត្វទាំងឡាយ. ២០-អកាលមេឃ គឺភ្លៀងពុំជួរកាល ក៏បង្អុរចុះមក. ២១-ទឹកផុះឡើងហូរចេញអំពីផែនដី. ២២-ពួកបក្សី ក៏លះបង់ដំណើរទៅតាមអាកាស. ២៣-នទីធំតូចដែលមានទឹកហូរទៅ ក៏ឈប់ហូរ. ២៤-ទឹកក្នុងមហាសមុទ្រ ក៏ត្រឡប់ជាមានរសផ្អែម. ២៥-ផ្ទៃផែនដីដេរដាសដោយផ្កាឈូក ៥ពណ៌. ២៦-ផ្កានៃរុក្ខជាតិនិងតិណជាតិ ដែលឋិតនៅលើគោកនិងក្នុងទឹក ក៏រីកស្គុសស្គាយទាំងអស់. ២៧-ដើមឈើទាំងឡាយ មានផ្ការីកចេញអំពីដើមខ្លះ រីកចេញអំពីមែកខ្លះ. ២៨-ដើមឈូកផុះទម្លាយចេញអំពីផ្ទៃថ្ម ៧ ដើមត្របំដុំថ្ម. ២៩-ផ្កាឈូករីកសំយុងចុះមកឯអាកាស. ៣០-មានភ្លៀងផ្កាបង្អុរចុះមកជុំវិញទាំងអស់. ៣១-មានតូរ្យតន្ត្រីទិព្វប្រគុំនាអាកាស. ៣២-លោកធាតុទាំង ១ម៉ឺន វិលទៅជុំវិញ ដូចជាសំណុំផ្កាកម្រងដែលគេបោះគ្រវែងទៅឯអាកាស សុទ្ធសឹងតែប្រោះព្រំដោយគ្រឿងក្រអូបមានលំអង់ឆើតឆាយ ។ បុព្វនិមិត្តទាំង ៣២ ប្រការនេះ កើតមានជាមហាស្ចារ្យ ចំពោះតែក្នុងវេលានោះប៉ុណ្ណោះ ។

លុះដល់វេលាភ្លឺច្បាស់ ព្រះនាងតើនឡើងហើយ ក៏ស្ដេចទៅក្រាបបង្គំទូលសួរនូវសុបិននិមិត្តនោះ ចំពោះព្រះបាទសុទ្ធោទនៈ ជាព្រះស្វាមី ។ ព្រះរាជាទ្រង់ត្រាស់បង្គាប់រាជបុរស ឱ្យអញ្ជើញពួកព្រាហ្មណ៍ ៦៤ នាក់មកទាយ. ព្រាហ្មណ៍ទាំងនោះ ក៏ក្រាបបង្គំទូលថ្វាយទំនាយតាមប្រភេទគ្រប់ប្រការថា ព្រះរាជទេវីនឹងមានព្រះរាជបុត្រមួយព្រះអង្គ ប្រកបដោយលក្ខណៈគ្រប់យ៉ាង. ហើយទាយតទៅទៀតថា បើប្រសិនជាព្រះរាជឱរសនោះនៅសោយរាជ្យក្នុងនគរ នឹងបានជាស្ដេចចក្រពត្តិ. បើចេញពីនគរទៅបួស នឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គស្រោចស្រង់សត្វលោក ។

ចប់គព្ភោក្កន្តិកថា

## ៣-គព្ភទុដ្ឋានកថា

តាំងអំពីថ្ងៃដែលព្រះបរមពោធិសត្វចាប់បដិសន្ធិមក មានទេវបុត្រទាំង ៤ អង្គ ដែលមានហត្ថាកាន់ព្រះខ័ន មកជួយរក្សាការពារនូវសេចក្ដីអន្តរាយក្រែងកើតមានដល់ព្រះបរមពោធិសត្វព្រមទាំងមាតា ដរាបគ្រប់ ១០ ខែ គត់ជាកំណត់ ។

ចំណែកខាងព្រះបរមពោធិសត្វ ដែលឋិតនៅក្នុងឧទរព្រះមាតា ព្រះអង្គគង់ពែនភ្នែនបែរព្រះភ័ក្ត្រទៅខាងឧទរព្រះមាតា. ព្រះបិដ្ឋិ (ខ្នង) ក៏បែរទៅខាងព្រះបិដ្ឋិព្រះមាតាដែរ.មិនមែនដូចសាមញ្ញសត្វទាំងឡាយដទៃឡើយ ។ ព្រះនាងទេវី លុះទ្រង់គភ៌គ្រប់បរិបូណ៌ហើយ ទ្រង់មានព្រះបំណងនឹងយាងទៅកាន់ក្រុងទេវទហៈ ដែលជាជាតិភូមិនៃព្រះនាង. ទើបក្រាបបង្គំទូលលាព្រះស្វាមី ។ ព្រះរាជាទ្រង់អនុញ្ញាតហើយទ្រង់ត្រាស់បង្គាប់ឱ្យពួករាជសេវកា-

មាត្យ តាក់តែងរាជវិធីតាំងពីនគរកបិលពស្តុ ដរាបដល់នគរទេវទហៈ ។ លុះដល់ក្នុងបុព្វណ្ហសម័យថ្ងៃពេញបូណ៌មីនៃខែអាសាឍ ព្រះនាងទេវីក៏ក្រាបបង្គំលាព្រះរាជា ហើយស្ដេចទៅដោយសុវណ្ណសិវិកា (វិមាស) មានសេនាយោធាអាមាត្យជាច្រើនហែហមទៅ. លុះដល់ដើមសាលព្រឹក្សមួយដើម នៅត្រង់ព្រំដែនអាណាខេត្តនគរទាំងពីរគឺ នគរកបិលពស្តុ និងនគរទេវទហៈ ដែលគេហៅថាព្រៃលុម្ពិនី ព្រះនាងទេវីក៏មានព្រះរាជហឫទ័យនឹកចង់ទស្សនាការក្រសាលព្រៃនោះឯង. រាជសេវកាមាត្យ ក៏អញ្ជើញព្រះនាងចូលទៅក្នុងព្រៃសាលវ័ន។ ព្រះនាងស្ដេចទៅដល់ខាងក្រោមដើមសាលព្រឹក្សមួយដើម មានព្រះរាជហឫ-ទ័យចង់ឈោងតោងមែកសាលព្រឹក្សនោះ ប៉ុន្តែមិនអាចនឹងឈោងព្រះហស្តទៅចាប់បានឡើយ ។ ឯមែកសាលព្រឹក្សនោះ ហាក់ដូចជាមានវិញ្ញាណ ក៏ទោរទន់ចុះមកថ្វាយព្រះនាងចាប់. កាលបើព្រះនាងឈោងចាប់នូវមែកសាលព្រឹក្សនោះបានហើយ. ខណៈនោះ ខ្យល់កម្មជវាតក៏បណ្ដាលកំរើកឡើងក្នុងព្រះឧទរនៃព្រះនាងទេវី ។ មហាជនបានដឹងហេតុ ក៏យកសន្ទិយា (រនាំង) ទៅបិទបាំងថ្វាយខាងក្រោមសាលព្រឹក្ស ហើយថយចេញមក ។ ទេវតាទាំងមួយម៉ឺនលោ-កធាតុក៏មកប្រជុំព្រមគ្នាក្នុងទីនោះ ។ ឯព្រះបរមពោធិសត្វ ក៏ប្រសូតចាកឧទរនៃព្រះមាតាក្នុងវេលានោះ មានព្រះកាយដ៏បរិសុទ្ធស្អាត ល្អឥតមានសៅហ្មងប្រឡាក់ដោយមន្ទិលអ្វីឡើយ ។ ចំណែកខាងសត្វដទៃ វេលាសំរាលមានខ្យល់កម្មជវាតកំរើកបក់ឡើង បណ្ដាលឱ្យមានជើងទៅខាងលើ ក្បាលសំយុងចុះក្រោម រមែងមានសេចក្ដីតក់ស្លុតរន្ធត់រងទុក្ខលំបាកយ៉ាងខ្លាំង ចេញមកតាមទ្វារមាសនៃមាតាប្រឡាក់ដោយមន្ទិលមិនស្អាតយ៉ាងណា. ឯព្រះបរមពោធិ-សត្វវេលាប្រសូត មិនមែនដូចជាសត្វដទៃយ៉ាងនោះទេ ប្រៀបដូចជាធម្មកថិក

ចុះអំពីធម្មាសនៈ ពុំនោះសោត ដូចជាបុរសចុះមកអំពីបង្អោង ។

ក្នុងខណៈដែលព្រះបរមពោធិសត្វប្រសូតនោះ មានធារទឹក២ហូរធ្លាក់ចុះមកអំពីអាកាសស្រោចស្រពថ្វាយ មួយអន្លើនឹងព្រះមាតា. មានសុទ្ធាវាសមហាព្រហ្មទាំង ៤អង្គ ចុះមកទទួលព្រះបរមពោធិសត្វដោយបណ្តាញមាស. តមក ចាតុម្មហារាជទាំង ៤អង្គ ក៏ទទួលអំពីមហាព្រហ្ម. ពួកមនុស្សទទួលយកអំពីចាតុម្មហារាជមកទៀត ។ ព្រះមហាបុរសទ្រង់ចុះអំពីដៃនៃមនុស្សហើយទ្រង់ប្រថាប់ឈរលើប្រឹថពី បែរព្រះភ័ក្ត្រទៅទិសខាងកើត ទ្រង់បានទទួលពាក្យសរសើរអំពីទេវតានិងមនុស្សទាំងឡាយថា ក្នុងលោកនេះ ឥតមានបុគ្គលណាស្មើនឹងព្រះអង្គឡើយ. ទ្រង់ប្រមើលមើលទៅគ្រប់ទិសទាំង ១០ គឺទិសធំ ៤ ទិសតូច ៤ និងទិសក្រោមទិសលើ ពុំឃើញមាននរណាមួយស្មើនឹងព្រះអង្គ. ទើបទ្រង់កំណត់ក្នុងព្រះទ័យថា "នេះជាទិសខាងជើង" ហើយទ្រង់បែរព្រះភ័ក្ត្រឆ្ពោះទៅទិសខាងជើង. ទ្រង់ស្តេចយាងទៅអស់ ៧ជំហាន. ព្រហ្មបាំងស្វេតច្ឆ័ត្រថ្វាយ, សុយាមទេវបុត្រ កាន់វាលវិជនី[១] បក់ថ្វាយ, ទេវតាទាំងឡាយឯទៀតកាន់រាជកកុធភណ្ឌទាំង ៥ តាមហែព្រះអង្គ. លុះដល់ជំហានទី ៧ ទ្រង់ប្រថាប់ឈរ ទ្រង់បញ្ចេញនូវអាសភិវាចារបស់ឧសភបុរស[២] បន្លឺសីហនាទថា :

**អគ្គោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស**
**ជេដ្ឋោហមស្មិ លោកស្ស អយមន្តិមា ជាតិនត្ថិទានិ បុនព្ភវោ ។**

"ខ្លួនអញជាកំពូលនៃលោក, ខ្លួនអញជាបុគ្គលប្រសើរជាងគេក្នុងលោក,

១-ផ្លិតសក់កន្ទុយសត្វចាមរីដែលមានសរសៃឆ្មារសម្បុរស្អាត ។ វាលវិជនីនេះ រាប់ចូលក្នុងរាជកកុធភណ្ឌទាំង ៥ យ៉ាង ។ ២- បុរសដូចជាឧសភៈ គឺមហាបុរសប្រសើរបំផុត ឥតមានបុគ្គលណាមួយប្រៀបផ្ទឹម បាន (ហៅថា បុរិសាសភៈ ក៏បាន) ។

**ខ្លួនអញជាច្បងជាងគេទាំងអស់ក្នុងលោក, ជាតិនេះ ជាកំណើតចុងក្រោយបំផុតរបស់អញ, អំណើះតទៅមុខ អញគ្មានកើតទៀតឡើយ"**

ព្រះអង្គទ្រង់ប្រសូតនៅលុម្ពិនីឧទ្យាន នាថ្ងៃសុក្រ **ពេញបូណ៌មី** ខែ **ពិសាខ ឆ្នាំច** វេលាថ្ងៃជិតត្រង់ ។

ក្នុងថ្ងៃដែលព្រះមហាសត្តប្រសូតនោះ មានសហជាតវត្ថុដែលកើតដំណាលគ្នាក្នុងថ្ងៃនោះដែរ ៧ ប្រភេទ គឺ: *ព្រះនាងពិម្ពាទេវី ១. ឆន្នអាមាត្យ ១ កាឡុទាយិអាមាត្យ ១. ព្រះរាជកុមារនាមអានន្ទ ១. កណ្ឋកអស្សរាជ ១. មហាពោធិព្រឹក្ស ១. កំណប់ទ្រព្យទាំងបួន ១* ។ ឯកំណប់ទ្រព្យទាំង ៤ នោះ មួយឈ្មោះ *សង្ខនិធិ* មានទំហំប្រមាណ ១គាវុត, មួយឈ្មោះ *ឯលនិធិ* មានទំហំប្រមាណកន្លះយោជន៍, មួយឈ្មោះ *ឧប្បលនិធិ* មានទំហំប្រមាណ ៣គាវុត និងមួយទៀតឈ្មោះ *បុណ្ឌរីកនិធិ* មានទំហំប្រមាណ ១ យោជន៍ ។

វេលានោះ ពួកក្សត្រទាំងពីរនគរបានអញ្ជើញព្រះនាងមាយាទេវី ឱ្យស្ដេចត្រឡប់ទៅកាន់នគរកបិលពស្ដុវិញ មួយអន្លើដោយព្រះរាជបុត្រ ហើយអញ្ជើញព្រះរាជបុត្រ ទៅថ្វាយព្រះបាទសុទ្ធោទនៈ ជាព្រះវររាជបិតា ។ លុះកន្លងទៅបាន ៧ ថ្ងៃ ព្រះនាងមាយាទេវីក៏ទ្រង់សោយព្រះវិលាល័យ ទៅឧប្បត្តិកចាប់កំណើតជាទេវបុត្រនាឋានតុសិតទេវលោក. ឯព្រះរាជបុត្រនោះ ព្រះរាជាបានផ្ទុកផ្ដាក់ឱ្យព្រះនាងមហាបជាបតិគោតមី ជាព្រះមាតុច្ឆាបីបាច់រក្សាដូចព្រះមាតាបង្កើត ។

ក្នុងថ្ងៃដដែលនោះ ពួកទេវតាដែលនៅក្នុងឋានតាវតឹង្សទេវលោក មានព្រះឥន្ទ្រាធិរាជជាដើម មានចិត្តត្រេកអរសាទរពោលចរចារដល់គ្នានឹងគ្នាថា *"ព្រះរាជបុត្ររបស់ព្រះបាទសុទ្ធោទនៈ ដែលប្រសូតហើយនោះនឹងបាន*

*ត្រាស់ជាព្រះពុទ្ធ ទ្រង់សំដែងធម្មចក្ក, ពួកយើងនឹងបានឃើញនូវព្រះពុទ្ធជាពុំខាន*" ។ ទើបទេវតាទាំងឡាយទូទាំងទេវលោក នាំគ្នាថ្វាយពរសព្ទសាធុការ ទាំងធ្វើសក្ការបូជាដ៏ច្រើនក្រៃលែងផង ។

ចប់ គព្ភវុដ្ឋានកថា

## ៤. លក្ខណព្យាករណកថា

សម័យនោះ តាបសឈ្មោះ **កាឡទេវិល**[១] ជាអ្នកបាននូវសមាបត្តិ ៨ មានឫទ្ធិច្រើន ជារាជកុលុបកៈ (ជីតុន) នៃព្រះបាទសុទ្ធោទនៈ លោកបានទៅកាន់ឋានតាវតិង្សទេវលោក ដោយឥទ្ធិពលនៃឈាន បានឮពាក្យទេវតាចរចាគ្នាដូច្នោះហើយ ក៏ចុះចាកទេវលោកមក ចូលទៅកាន់ព្រះរាជនិវេសន៍នៃព្រះបាទសុទ្ធោទនៈ ថ្វាយព្រះពរសួរថា "បពិត្រមហារាជ ! ព្រះរាជបុត្ររបស់ព្រះអង្គប្រសូត្រហើយឬ ? អាត្មាភាពចង់ឃើញ" ។ ព្រះរាជាទ្រង់បង្គាប់ពួកមេនំឱ្យអញ្ជើញព្រះរាជកុមារមក ដើម្បីឱ្យថ្វាយបង្គំតាបស ។ ខណៈនោះ ព្រះមហាពោធិសត្វមិនថ្វាយបង្គំ បែរជាលើកព្រះបាទទាំងពីរដាក់លើជដានៃតាបសវិញ ។ តាបសក៏ក្រោកចេញពីកន្លែង ហើយផ្គងអញ្ជលីប្រណម្យចំពោះព្រះមហាសត្ត ។ ព្រះវររាជបិតាទតឃើញហេតុអស្ចារ្យនោះ ក៏សំពះព្រះរាជបុត្ររបស់ព្រះអង្គ ដោយសំគាល់ថា ដូចជាមហាព្រហ្ម[២] ការសំពះព្រះរាជបុត្រនេះ (ជាគ្រាទី ១) ។

តាបសបានឃើញលក្ខណសម្បត្តិនៃព្រះមហាសត្វហើយ ក៏ពិចារណា

១-ហៅថា ទេវល ឬអសិតៈ ឬក៏អសិតតាបស ក៏បាន ។ ២-ព្រះបាទសុទ្ធោទនៈ ទ្រង់គោរពលទ្ធិព្រាហ្មណ៍ដែលលើកដំកើងមហាព្រហ្មជាធំ. ព្រោះហេតុនោះ បានជាទ្រង់សំគាល់ព្រះរាជបុត្ររបស់ព្រះអង្គថាមានបុណ្យអស្ចារ្យ ដូចជាមហាព្រហ្ម ។

ថា "ព្រះរាជកុមារនេះនឹងបានត្រាស់ជាព្រះពុទ្ធឬទេ ?" ។ ទើបដឹងច្បាស់ដោយញាណថា "ព្រះរាជកុមារនេះ នឹងបានត្រាស់ជាព្រះពុទ្ធឥតសង្ស័យឡើយ" ។ លុះដឹងយ៉ាងនេះហើយ ក៏ញញឹម ហើយយំតទៅទៀត, មនុស្សទាំងឡាយឃើញហើយ ក៏សួរអំពីហេតុដែលញញឹម និងការណ៍យំនោះ ។ តាបសបានព្យាករហេតុនោះថា ដែលអាត្មាញញឹមនោះ ព្រោះត្រេកអរចំពោះព្រះអយ្យបុត្រនេះ ដែលនឹងបានត្រាស់ជាព្រះពុទ្ធ, ដែលអាត្មាយំនោះ ព្រោះស្តាយ ដោយខ្លួនអាត្មាជាមនុស្សអភ័ព្វ មិនអាចនឹងរស់នៅទាន់កាលដែលព្រះអយ្យបុត្រ[១] នេះ នឹងបានត្រាស់ជាព្រះពុទ្ធឡើយ ។

លំដាប់នោះ តាបសពិចារណាថា បណ្តាពួកញាតិទាំងអស់របស់អាត្មាអញ នឹងមានញាតិណាមួយបានទាន់ព្រះអយ្យបុត្រនេះបានត្រាស់ជាព្រះពុទ្ធឬទេ ?, លុះពិចារណាទៅក៏បានដឹងថា នាលកកុមារជាក្មួយនឹងបានទាន់ ។ ទើបតាបសថ្វាយព្រះពរលាទៅផ្ទះប្អូនស្រីនៃខ្លួន, លុះទៅដល់ហើយក៏បង្គាប់ទៅប្អូនស្រីឱ្យហៅនាលកមាណព មកប្រាប់ថា "ម្នាលនាលកៈ ! ព្រះរាជបុត្រនៃព្រះបាទសុទ្ធោទនៈ កន្លង ៣៥ ឆ្នាំ ពីឆ្នាំនេះទៅ នឹងបានត្រាស់ជាព្រះពុទ្ធ, ឯងនឹងបានទាន់ជួបព្រះពុទ្ធនោះ, ចូរឯងបួសក្នុងថ្ងៃនេះឱ្យហើយទៅ" ។ នាលកកុមារបានស្តាប់ពាក្យតាបសជាឪពុកធំហើយ ក៏គិតថា "ឪពុកធំអញមិនមែនដឹកនាំអញឱ្យប្រកបក្នុងអំពើឥតប្រយោជន៍ទេ" ។ ខណៈនោះ នាលកកុមារឱ្យគេនាំយកសំពត់កាសាយៈ និងបាត្រដីអំពីផ្សារមក, ឱ្យគេកោរសក់ និងពុកមាត់ពុកចង្កា រួចហើយស្លៀកដណ្តប់សំពត់កាសាយៈ ផ្គងអញ្ជលីចំពោះទៅមហាសត្តថា "បុគ្គលណាជាឧត្តមបុរសក្នុងលោក, ផ្នួសរបស់អាត្មាអញនេះ សូមឧទ្ទិស

១-អយ្យបុត្រ ប្រែថា "បុត្រនៃលោកជាម្ចាស់" (ព្រះអង្គម្ចាស់) ។

ថ្វាយចំពោះបុគ្គលនោះ" ហើយក៏ច្រកបាត្រក្នុងស្លោក ស្ពាយលើចង្កូយស្មាដើរចូលទៅធ្វើសមណធម៌ក្នុងព្រៃហិមពាន្ត [១] ។

នៅថ្ងៃទី ៥ ក្រោយដែលព្រះមហាបុរសប្រសូតមក ព្រះវររាជបិតាបានរៀបតាំងពិធីរើសព្រះនាមថ្វាយ ទើបទ្រង់បញ្ជាឱ្យតាក់តែងព្រះរាជវាំងប្រោះព្រំដោយគ្រឿងក្រអូប ព្រមទាំងរោយរាយផ្កាផ្សេងៗ ។ ខណៈនោះព្រះរាជាទ្រង់មានព្រះតម្រាស់ឱ្យអញ្ជើញព្រាហ្មណ៍ ១០៨ រូប មកអង្គុយលើអាសនៈ អង្គាស (ជប់លៀង) ដោយភត្តាហារដ៏ប្រណីត រួចស្រេចហើយឱ្យព្រាហ្មណ៍ទាំងនោះត្រឡប់ទៅវិញ ទុកតែព្រាហ្មណ៍ ៨ រូបដែលមាននាមថា រាមព្រាហ្មណ៍១, ធជព្រាហ្មណ៍១, លក្ខណព្រាហ្មណ៍១, សុជាតព្រាហ្មណ៍១, ភោជព្រាហ្មណ៍១, សុយាមព្រាហ្មណ៍១, សុទន្តព្រាហ្មណ៍១, កោណ្ឌញ្ញព្រាហ្មណ៍ ១, សុទ្ធតែជាអ្នកចេះចាំស្ទាត់ក្នុងត្រៃវេទ ជាងព្រាហ្មណ៍ទាំងអស់ ។ បណ្ដាព្រាហ្មណ៍ទាំង ៨ រូបនោះ ព្រាហ្មណ៍ ៧ រូបលើកដៃពីរឡើង ទាយជាពីរយ៉ាងថា ព្រះរាជកុមារដែលប្រកបដោយលក្ខណសម្បត្តិបែបនេះ បើនៅគ្រប់គ្រងផ្ទះ នឹងបានសោយរាជ្យជាស្ដេចចក្រពត្តិ, បើចេញទៅបួស នឹងបានត្រាស់ជាព្រះពុទ្ធ ។ ចំណែកខាងកោណ្ឌញ្ញព្រាហ្មណ៍ ដែលនៅក្មេងជាងព្រាហ្មណ៍ទាំងនោះ បានឃើញលក្ខណសម្បត្តិហើយ ក៏លើកតែម្រាមដៃមួយថ្វាយទំនាយថា ព្រះកុមារនេះ មិនមែនជាអ្នកនៅគ្រប់គ្រងផ្ទះទេ ពិតជានឹងចេញទៅបួសហើយបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ លំដាប់ពីនោះមក ព្រាហ្មណ៍ទាំងឡាយក៏បានថ្វាយព្រះនាមដល់ព្រះរាជកុមារថា "**សិទ្ធត្ថ**" ។ លុះកាលជាខាងក្រោយ

១-គួរយល់ថា ក្នុងសម័យនោះ បានជាមានបាត្រនិងសំពត់កាសាយៈសំរាប់លក់នៅផ្សារ ព្រោះពួកពាហិរបព្វជិតដែលត្រូវការប្រើបាត្រដី និងសំពត់ជ្រលក់ទឹកអម្ចត់ ក៏មានច្រើនណាស់ ។

មក ព្រះបរមពោធិសត្វមានព្រះនាមថា **គោតម** ដែលជាព្រះនាមជាប់ដោយអំណាចនៃគោត្ររបស់ព្រះអង្គ[១] ។ គ្រានោះ ព្រះរាជាទ្រង់ត្រាស់សួរពួកព្រាហ្មណ៍ថា ឱរសរបស់យើងនឹងឃើញនូវអ្វីទើបចេញបួស ? ព្រាហ្មណ៍ក្រាបទូលថា ព្រះរាជឱរសរបស់ព្រះអង្គនឹងបានឃើញនូវនិមិត្ត ៤ យ៉ាងគឺ មនុស្សជរា១, មនុស្សឈឺ១, មនុស្សស្លាប់១, អ្នកបួស១ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យព្រាហ្មណ៍ក្រាបទូលហើយ ទើបទ្រង់ត្រាស់បង្គាប់រាជអាមាត្យថា *"ចាប់ដើមតាំងពីថ្ងៃនេះទៅ អ្នកទាំងឡាយកុំឱ្យមនុស្សបែបនេះ ចូលមកកាន់សំណាក់នៃបុត្រយើងឡើយ"*។ ហើយទ្រង់ចាត់តាំងឱ្យមានអ្នកចាំរក្សាចម្ងាយ១គាវុតគ្រប់ទិសទាំង ៤ ដើម្បីការពារនូវមនុស្សមានសភាពដូច្នោះ កុំចូលមកប៉ះប្រទះព្រះនេត្រនៃព្រះបរមពោធិសត្វបានឡើយ ។

លំដាប់នោះ ព្រាហ្មណ៍ទាំង ៨រូបត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួនវិញហើយ ហៅកូនទាំងឡាយមកផ្ដាំថា ម្នាលអ្នកទាំងឡាយ ! យើងចាស់ហើយ, ព្រះរាជឱរសរបស់ព្រះបាទសិរីសុទ្ធោទនៈ គង់នឹងបានត្រាស់ជាព្រះសព្វញ្ញុពុទ្ធ, យើងនឹងមិនទាន់ទេ, កាលបើព្រះរាជឱរសនោះចេញទ្រង់ព្រះផ្នួសបានត្រាស់ជាព្រះពុទ្ធហើយ, អ្នកទាំងឡាយចូរទៅបួសក្នុងសាសនានៃព្រះពុទ្ធនោះចុះ។ បណ្ដាព្រាហ្មណ៍ទាំង ៨ រូបនេះ ៧ រូបខាងដើមបានឋិតនៅជរាបដល់អស់អាយុហើយ ក៏ធ្វើមរណកាលទៅកើតតាមយថាកម្មរបស់ខ្លួន មុនពេលដែលព្រះបរមពោធិសត្វចេញពីនគរទៅទ្រង់ព្រះផ្នួស, ឯព្រាហ្មណ៍ទី ៨ គឺកោណ្ឌញ្ញៈ មានជីវិតរស់នៅឡើយ ក្នុងសម័យនោះ ។

---

១- *សិទ្ធត្ថ* ប្រែថា អ្នកមានប្រយោជន៍សំរេចហើយ ឬថា អ្នកញុំាងប្រយោជន៍ឱ្យសំរេចដល់សត្វលោក ។ ព្រះអង្គជាគោតមគោត្រ (ពូជពង្សព្រះអាទិត្យ)។ ព្រះនាមរបស់ព្រះអង្គជា *សិទ្ធត្ថ* ឬ *សិទ្ធត្ថគោតម* ក៏មាន, ជា *អង្គីរស* ឬ *អង្គីរសគោតម* ក៏មាន ។

ចំណែកខាងពួកព្រះញាតិប៉ែតសិបពាន់ពីរដង ក៏បានប្ដេជ្ញាគ្នាថា ព្រះសិទ្ធត្ថរាជកុមារនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្ដី នឹងបានជាស្ដេចចក្រពត្តិក្ដី យើងនឹងថ្វាយបុត្រមួយម្នាក់ៗ គ្រប់ៗគ្នា ។ តមក ព្រះរាជាទ្រង់រើសយកស្ត្រីទាំងឡាយ ដែលមានរូបសម្ផស្សល្អ ប្រាសចាកទោសទាំងពួង ឱ្យធ្វើជាមេនំថែរក្សាព្រះបរមពោធិសត្វ ៗ ទ្រង់ចំរើនរុងរឿងជាមួយនឹងបរិវារ និងសិរីសម្បត្តិតរៀងមក ។

ចប់ លក្ខណព្យាករណកថា

## ៥.វប្បមង្គលកថា

ថ្ងៃជាខាងក្រោយមក មានការតាំងពិធីច្រត់ព្រះនង្គ័ល គឺភ្ជួរស្រែជាដំបូងឬសាបស្រូវដែលហៅថា "វប្បមង្គល (មង្គលសាបព្រោះ)" ថ្ងៃនោះ ពួកអាមាត្យតាក់តែងព្រះនគរទាំងមូលដូចជាវិមាននៃទេវតា ។ ព្រះបាទសុទ្ធោទនៈ ទ្រង់ឱ្យអញ្ជើញព្រះរាជបុត្រទៅ ដោយមាននាម៉ឺនមុខមន្ត្រីរេហ៍ពលសកលយោធា និងស្រីស្នំហែហមទៅកាន់កន្លែងនោះ ។ លុះស្ដេចយាងទៅដល់ទីនោះ ទ្រង់ឱ្យរៀបចំទីសេយ្យាថ្វាយព្រះរាជបុត្រធំខាងក្រោមដើមជម្ពូព្រឹក្ស[១] មួយដើម ដែលមានស្លឹកក្រាស់ ម្លប់ជិតស្និទ្ធល្អ មានសណ្ឋានដូចជាមណ្ឌប (បារាំ) ឱ្យចងពិតានវិចិត្រដោយផ្កាយមាសពីខាងលើ. ឱ្យបិទបាំងដោយរនាំងជុំវិញ. ឱ្យពួកមេនំមេនាងនៅរក្សាព្រះរាជបុត្រក្នុងទីនោះ ។ ព្រះរាជាទ្រង់ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ដោយមានពួករាជសេវកាមាត្យជាបរិវារ ទ្រង់ស្ដេចទៅច្រត់ព្រះនង្គ័ល ។ មេនំទាំងឡាយឱ្យព្រះពោធិសត្វធំហើយ ក៏នាំ

១-ដើមព្រីង ។

ផ្កាចេញទៅខាងក្រៅ ដើម្បីមើលស្ដេចច្រត់ព្រះនង្គ័ល ។ ខណៈនោះ ព្រះមហាសត្វបានឱកាសស្ងាត់ ក្រឡេកមើលទៅមិនឃើញមាននរណាមួយ ក៏ក្រោកចាកទីសេយ្យា គង់ពែនព្រះភ្នែនចំរើនអានាបានស្សតិកម្មដ្ឋាន[1] ញ៉ាំងបឋមជ្ឈានឱ្យកើតឡើង ។ ឯពួកមេនំដែលដើរចេញពីកន្លែងនោះ ទៅយូរបន្តិចក៏នឹកឃើញថា ព្រះអយ្យបុត្រគង់នៅតែមួយព្រះអង្គឯង ហើយក៏ត្រឡប់វិលមកវិញ ឃើញព្រះមហាបុរសកំពុងតែពែនព្រះបាទ នៅនឹងថ្កល់ក្នុងម្លប់ជម្ពូព្រឹក្ស ដែលនៅតែកន្លែងមួយ មិនជ្រែបែរទៅតាមដំណើរព្រះអាទិត្យឡើយ។ គួរឱ្យអស្ចារ្យណាស់ ម្លប់ឈើឯទៀតៗសុទ្ធតែងាកបែរទៅតាមមណ្ឌលព្រះអាទិត្យ ។ ព្រះបាទសុទ្ធោទនៈកាលបើជ្រាបសេចក្ដីនោះហើយ ទ្រង់ស្ដេចមកដោយរួសរាន់ ឃើញបាដិហារ្យអស្ចារ្យដូច្នោះ ក៏សំពះសរសើរបារមីព្រះរាជបុត្រ ក្នុងគ្រានោះម្ដងទៀត ( ជាគ្រាទី ២ ) ។

ចប់ វប្បមង្គលកថា

## ៦_សិប្បទេសនាកថា

ព្រះបរមពោធិសត្វមានវ័យចំរើនជាលំដាប់ ដរាបដល់បានព្រះជន្ម១៦ឆ្នាំ. ទើបព្រះវររាជបិតាទ្រង់ចាត់ការឱ្យជាងសាងសង់ប្រាសាទ ៣ ខ្នង ដ៏សមគួរដល់រដូវទាំង ៣ ថ្វាយដល់ព្រះរាជឱរសគង់ ។ ប្រាសាទមួយមានជាន់ ៩. ប្រាសាទមួយមានជាន់ ៧. ប្រាសាទមួយមានជាន់ ៥ ។ ព្រះមហាសត្វទ្រង់សោយមហាសម្បត្តិ គង់នៅសប្បាយក្នុងប្រាសាទទាំងបីខ្នងតាមរដូវ មានស្រីរបាំបួនម៉ឺននាក់ ចោមរោមគាល់បំរើដោយតូរ្យតន្ត្រីជាប្រក្រតី ហាក់ដូចជា

១-កម្មដ្ឋាន ដែលកំណត់ដោយខ្យល់ដកដង្ហើមចេញចូល ។

ទេវតាដែលមាននាងទេពអប្សរបវរកញ្ញាចោមរោមជាបរិវារ ។ ព្រះវរបិតាទ្រង់ឱ្យរៀបអភិសេកព្រះរាជឱរសក្នុងរាជសម្បត្តិ ជាមួយព្រះនាងពិម្ពាយសោធរា ជាព្រះរាជធីតានៃព្រះបាទសុប្បពុទ្ធ ឱ្យជាអគ្គមហេសី ។

កាលដែលព្រះបរមពោធិសត្វ កំពុងតែសោយសិរីសុខក្នុងរាជសម្បត្តិ ថ្ងៃមួយពួកញាតិរិះគន់ថ្កោលទោសថា សិទ្ធត្ថកុមារ រវល់ខ្វល់ខ្វាយតែនឹងល្បែង ឥតមានសិក្សាសិល្បសាស្ត្រអ្វីសោះ ប្រសិនបើមានសឹកសង្គ្រាមកើតឡើងដល់ព្រះនគរ តើនឹងធ្វើដូចម្តេចទៅ ? ព្រះបាទសុទ្ធោទនៈទ្រង់ជ្រាបហេតុនោះហើយ ក៏ឱ្យអញ្ជើញព្រះពោធិសត្វមកប្រាប់ថា ម្នាលកូន ! ពួកព្រះញាតិរបស់អ្នក តែងនិយាយថា សិទ្ធត្ថកុមារឥតបានសិក្សាវិជ្ជាអ្វីសោះ រវល់ខ្វល់តែនឹងល្បែង. តើអ្នកសំគាល់នូវកាលដែលដល់ហើយត្រឹមប៉ុណ្ណេះឬ ? ព្រះមហាបុរសទូលថា បពិត្រព្រះបិតា ! ខ្ញុំព្រះអង្គមិនមានកិច្ចត្រូវសិក្សាសិល្បសាស្ត្រអ្វីទៀតទេ. សូមព្រះវរបិតាឱ្យប៉ាវគងទូងភេរីឱ្យដំណឹងដល់ពួកសក្យៈ ជាព្រះញាតិទាំងអស់ថា ពីថ្ងៃនេះទៅ នៅ ៧ ថ្ងៃទៀត ខ្ញុំព្រះអង្គនឹងសំដែងសិល្បសាស្ត្រ បង្ហាញដល់ពួកព្រះញាតិទាំងអស់ ឱ្យឃើញចេស្តារាល់គ្នា ។ លុះដល់ថ្ងៃដែលកំណត់នោះ ព្រះបរមពោធិសត្វ ទ្រង់ឱ្យប្រជុំពួកខ្មាន់ធ្នូទាំងអស់ រួចហើយទ្រង់សំដែងសិល្បសាស្ត្រ ១២ យ៉ាង[១] មានវិជ្ជាបាញ់ធ្នូជាដើម ដល់ពួកព្រះញាតិ ជាវិជ្ជាស្ទាត់ជំនាញឥតមានខ្មាន់ធ្នូដទៃប្រៀបបាន ក្នុងកណ្តាលសន្និបាតនៃមហាជន ។ គ្រានោះ ពួកព្រះញាតិទាំងអស់ លែងមានសន្និះសង្ស័យរិះគន់ចំពោះព្រះអង្គតទៅទៀត ។

ចប់ សិប្បទេសនាកថា

១-មានសេចក្តីពិស្តារក្នុងសរភង្គជាតក ។

## ៧. មហាភិនិក្ខមនកថា

លុះសម័យតមក ព្រះបរមពោធិសត្វមានព្រះហឫទ័យនឹកភ្នកចង់ស្តេចចេញទៅក្រសាលឧទ្យាន, ទ្រង់មានព្រះរាជបញ្ជាឱ្យហៅសារថីមកបង្គាប់ឱ្យរៀបរាជរថថ្វាយ ។ សារថីក៏ទទួលរាជបញ្ជា ហើយចាត់ចែងរាជរថទឹមដោយសេះសិន្ធពជាមង្គលពីរគូរនាំមកថ្វាយ ។ ព្រះបរមពោធិសត្វ ទ្រង់ឡើងគង់លើរាជរថប្រាកដស្មើដោយវិមាននៃទេវតា ទ្រង់ស្តេចចេញសំដៅទៅកាន់ឧទ្យាន ។ លំដាប់នោះ ទេវតាទាំងឡាយគិតគ្នាថា កាលជាទីត្រាស់ដឹងនៃព្រះសិទ្ធត្ថកុមារជិតណាស់ហើយ យើងនឹងសំដែងនូវបុព្វនិមិត្តឱ្យប្រាកដ, ហើយក៏ឱ្យទេវបុត្រមួយអង្គនិម្មិតធ្វើជាមនុស្សចាស់ជរា មានធ្មេញបាក់ សក់ស្កូវ ខ្នងកោង ដៃកាន់ឈើច្រត់ញ័រទទ្រើក ដើរពីខាងមុខ, ឯព្រះបរមពោធិសត្វនិងសារថី បានឃើញមនុស្សជរានោះប្រាកដ ទើបព្រះអង្គទ្រង់សួរសារថីថា *មនុស្សនោះជាអ្វី ?* សារថីក្រាបបង្គំទូលសព្វគ្រប់ប្រការ, ព្រះអង្គក៏មានព្រះហឫទ័យសង្វេគ ហើយទ្រង់បង្គាប់ឱ្យសារថីបរព្រះរាជរថត្រឡប់វិលមកប្រាសាទវិញ ។ ព្រះបាទសិរីសុទ្ធោទនៈ ត្រាស់សួរសារថីថា ហេតុអ្វីបានជាកូនរបស់អញឆាប់វិលត្រឡប់មកវិញម្ល៉េះ ?

សារថីក្រាបបង្គំទូលថា ព្រះរាជឱរសទតឃើញមនុស្សជរា ។ ព្រះវររាជបិតាទ្រង់ព្រះតម្រិះថា កូនអញបានឃើញមនុស្សចាស់ទុព្វលភាពហើយ ក៏មុខជានឹងចេញទៅបួសជាពុំខាន ។ ទ្រង់ក៏ត្រាស់បង្គាប់ថា អ្នកទាំងឡាយ ចូរចាត់ចែងស្រីរបាំឱ្យច្រៀងរាំថ្វាយកូនអញយ៉ាងឆាប់ ដើម្បីកុំឱ្យនឹកភ្នកទៅរកបព្វជ្ជាឱ្យសោះ ។ មិនតែប៉ុណ្ណោះ ព្រះអង្គទ្រង់ដាក់កំហិតឱ្យរាជបុរសយាមល្បាតប្រាសាទនៃព្រះរាជបុត្រ កំណត់ទីកន្លះយោជន៍ជុំវិញ ដើម្បីការពារកុំឱ្យ

មនុស្សមានភេទចាស់ជរា ចូលមកជិតព្រះពោធិសត្វបានឡើយ ។

ចំណេរកាលពីនោះមក ព្រះពោធិសត្វទ្រង់ស្ដេចទៅកាន់ឧទ្យានម្ដងទៀត ទេវតានិម្មិតឱ្យឃើញមនុស្សមានព្យាធិ កំពុងឈឺចាប់បម្រះនទ្រៀល ទ្រង់សួរសារថី១ក៏ក្រាបទូលដូចមុន. ទ្រង់មានព្រះរាជហឫទ័យសង្វេគ. ស្ដេចត្រឡប់វិលមកប្រាសាទវិញ ។ ព្រះវររាជបិតា ទ្រង់បានជ្រាបហេតុដូច្នោះហើយ ក៏ទ្រង់ចាត់ការឱ្យរាជបុរសនៅចាំរក្សា មានទីចម្ងាយប្រមាណ ៣ គាវុត ជុំវិញប្រាសាទ ដើម្បីការពារកុំឱ្យមនុស្សមានព្យាធិចូលមកជិតព្រះរាជបុត្របានឡើយ ។

ចំណេរកាលតពីនោះមកទៀត ព្រះពោធិសត្វ ទ្រង់ស្ដេចទៅកាន់ឧទ្យានក្នុងគ្រាទី៣. ទេវតានិម្មិតឱ្យឃើញមនុស្សស្លាប់. ទ្រង់សាកសួរសារថី ១ ក៏បានក្រាបទូលតាមដំណើរ. ព្រះអង្គមានព្រះហឫទ័យសង្វេគ ហើយទ្រង់ធ្វើនិវត្តនាការវិលត្រឡប់មកប្រាសាទវិញ ។ ព្រះវរបិតា ទ្រង់ចាត់ការថែរក្សាព្រះពោធិសត្វ ដូចន័យមុនទៀត ។

ព្រះពោធិសត្វ ទ្រង់ស្ដេចទៅក្រសាលឧទ្យានក្នុងគ្រាទី ៤. ទេវតានិម្មិតឱ្យឃើញបព្វជិត(ភេទអ្នកបួស) មានសម្លៀកបំពាក់សមរម្យល្អ ក៏ត្រាស់សួរសារថីថា *មនុស្សនោះជាអ្វី ?* ដោយអានុភាពនៃទេវតាបញ្ចូលចិត្តសារថី១ យល់ហេតុការណ៍ដោយសព្វគ្រប់ ហើយក្រាបទូលព្រះមហាសត្វថា "សូមទ្រង់ព្រះមេត្តាប្រោស! នុ៎ះហៅថា ភេទបព្វជិត. ហើយក៏ពណ៌នាគុណរបស់បព្វជ្ជាថ្វាយព្រះអង្គក្នុងខណៈនោះ ។ ព្រះសិទ្ធត្ថរាជ ទ្រង់ព្រះសណ្ដាប់ហើយ មានសោមនស្ស ពេញព្រះហឫទ័យក្នុងភេទបព្វជ្ជា. ទើបព្រះអង្គស្ដេចយាងទៅក្រសាលឧទ្យាន. ទ្រង់ស្ដេចចុះស្រង់ក្នុងស្រះបោក្ខរណីជាមង្គល. ទ្រង់ក្រសាល

សប្បាយពេញមួយថ្ងៃ. លុះព្រះអាទិត្យអស្តង្គត ទ្រង់ទៅគង់លើផែនមង្គលសិលា. ទ្រង់មានព្រះបំណងនឹងឱ្យគេតែងព្រះអង្គដោយគ្រឿងអលង្ការ ។ គ្រានោះពួកស្រីបរិចារិកា យកសំពត់មានពណ៌ផ្សេងៗ ព្រមទាំងអាភរណាលង្ការនិងកម្រងផ្កាគ្រឿងក្រអូបមកតែងព្រះអង្គថ្វាយ ។ ខណៈនោះ អាសនៈរបស់ព្រះឥន្ទបណ្ដាលឱ្យក្ដៅខុសពីប្រក្រតី ទើបព្រះឥន្ទរំពឹងពិចារណាមើល ក៏បានឃើញកាលដែលគួរថ្វាយគ្រឿងអលង្ការដល់ព្រះបរមពោធិសត្វ. ទើបទ្រង់ត្រាស់ហៅវិស្សុកម្មទេវបុត្រមកបង្គាប់ថា ម្នាលវិស្សុកម្មៈ! ព្រះសិទ្ធត្ថរាជ នឹងចេញទ្រង់ព្រះផ្នួសក្នុងសម័យពាក់កណ្ដាលអធ្រាត្រយប់នេះ. ឯការទ្រទ្រង់នូវគ្រឿងអលង្ការរបស់ព្រះពោធិសត្វ ជាចុងក្រោយបំផុតត្រឹមនេះហើយ. ចូរអ្នកទៅកាន់ឧទ្យាន ឃើញព្រះមហាបុរសហើយ ចូរតែងគ្រឿងអលង្ការទាំងពួង ។ វិស្សុកម្មទេវបុត្រ បានទទួលទេវបញ្ជាហើយ ក៏និម្មិតខ្លួនក្លែងភេទជាខ្មាន់ព្រះកេសម្នាក់សំរាប់ព្រះអង្គ មកយកសំពត់ឈ្នួតអំពីដៃខ្មាន់ព្រះកេសម្នាក់ទៀត ហើយចូលទៅជូតថ្វាយ ។ វិស្សុកម្មទេវបុត្រជូតថ្វាយ ១០ ជុំ. សំពត់ឈ្នួតនោះ ក៏ក្លាយទៅជា ១ ហ្មឺនស្រទាប់ មានសណ្ឋានជាមោលី. មានលំអឆើត សមរម្យល្មមនឹងព្រះសិរនៃព្រះអង្គ ។ ព្រះមហាសត្វទ្រង់ជ្រាបថា សម្ផស្សដៃនេះ មិនមែនជាសម្ផស្សដៃនៃមនុស្សទេ. អ្នកនេះប្រាកដជាទេវតា ឥតសង្ស័យឡើយ ។ លុះខ្មាន់ព្រះកេសតែងព្រះអង្គរួចស្រេចហើយ ពួកព្រាហ្មណាចារ្យក៏សូត្រស្ដុតិវាចាសរសើរព្រះបារមី ថ្វាយជ័យមង្គលតាមពិធីព្រាហ្មណិក ។

នៅវេលានោះ ព្រះនាងពិម្ពាយសោធរាទ្រង់ប្រសូត្រព្រះរាជបុត្រ ឯព្រះរាជនិវេសនដ្ឋានក្នុងបរមរាជវាំងក្រុងកបិលពស្តុ ។ ព្រះបាទសិរីសុទ្ធោទនៈ

ទ្រង់ត្រាស់ប្រើរាជសេវកាមាត្យ ឱ្យទៅទូលព្រះរាជឱរសតាមដំណើរការណ៍ ។ កាលដែលព្រះមហាបុរសទ្រង់ជ្រាបថា ព្រះអគ្គមហេសីប្រសូត្រព្រះរាជបុត្រហើយ ព្រះអង្គលាន់ព្រះឱស្ឋថា "**រាហុលោ**[១] **ជាតោ ! ពន្ធនំ ជាតំ !** *(ឱ!) រាហូចាប់ហើយតើ ! ចំណងកើតហើយតើ !*" ។

ដោយហេតុដែលព្រះមហាសត្វលាន់ព្រះឱស្ឋថា "*រាហូចាប់ហើយតើ !*" ដូច្នេះ បានជាលុះសម័យតមកខាងមុខ ព្រះបាទសុទ្ធោទនៈទ្រង់បានជ្រាបការណ៍នេះហើយ ទើបទ្រង់ប្រទាននាមព្រះរាជនត្តា (ចៅប្រុស) របស់ព្រះអង្គថា "**រាហុល**" ។

លំដាប់នោះ ព្រះមហាបុរសរត្ន័ ទ្រង់ស្តេចឡើងគង់លើព្រះទីនាំងរាជរថវិចិត្រដោយលំអដ៏បវរ. សារថីក៏បរតាមលំដាប់មាគ៌ាជាព្រះរាជវិថីប្រទក្សិណក្រុង ហើយបរចូលក្នុងព្រះបរមរាជវាំង ។ វេលានោះ នាងខត្តិយកញ្ញា នាម**កិសាគោតមី**[២] កំពុងឋិតនៅនាផ្ទៃប្រាសាទជាន់ខាងលើ បានឃើញរូបសិរីនៃព្រះមហាសត្វ ដែលកំពុងគង់លើព្រះទីនាំងរាជរថ ក៏មានសោមនស្ស បន្លឺវាចាថា :

**និព្វុតា នូន សា មាតា និព្វុតោ នូន សោ បិតា**
**និព្វុតា នូន សា នារី យស្សាយំ ឦទិសោ បតិ ។**

"ព្រះសិទ្ធត្ថអង្គនេះ បើបានជាបុត្រនៃមាតាណា មាតានោះរលត់ទុក្ខដោយពិត. បើបានជាបុត្រនៃបិតាណា បិតានោះរលត់ទុក្ខដោយពិត. បើបាន

១-*រាហុលោ* ប្រែថា "រាហូចាប់" ឬថា "ត្រូវរាហូចាប់" មកពី *រាហុ*= "រាហូ" និង *លា* (អាទានេ)= "ចាប់" (លា > ល)=រាហុល. គឺព្រះមហាសត្វទ្រង់ប្រៀបព្រះអង្គទុកដូចជាព្រះចន្ទ, ប្រៀបព្រះរាជបុត្រទើបប្រសូតនោះ ទុកដូចជារាហូ ។ ២-នាងកិសាគោតមីនេះ ជាសក្យខត្តិយកញ្ញា ជាព្រះញាតិព្រះអង្គ មានគោត្រដូចព្រះអង្គដែរ, បុរសជា គោតម, ស្ត្រីជា គោតមី "គោត្រព្រះអាទិត្យ" ដូចជាអាទិច្ចពន្ធុដែរ ។

ជាស្វាមីនៃនារីណា នារីនោះរលត់ទុក្ខដោយពិត " ។

ព្រះមហាសត្វ ទ្រង់បានព្រះសណ្ដាប់ឧទានវាចានេះហើយ ក៏មានព្រះហឫទ័យរីករាយ ទ្រង់ឈ្វេងយល់ថា កាលបើភ្លើងរាគៈ ទោសៈ មោហៈរលត់ហើយ ទើបបានឈ្មោះថា រលត់ទុក្ខ. បើកិលេសទាំងពួងមានមានៈ និងទិដ្ឋិជាដើមរលត់ហើយ ទើបបានឈ្មោះថា រលត់ទុក្ខ. ក៏នាងខត្តិយកញ្ញានុ៎ះ បានញុំាងអាត្មាអញឱ្យឮនូវពាក្យពិរោះយ៉ាងនេះហើយ គួរតែអាត្មាអញលះបង់នូវឃរាវាសនេះ ហើយចេញទៅបួសដើម្បីស្វែងរកនិព្វាន ជាគ្រឿងរលត់ទុក្ខក្នុងថ្ងៃនេះកុំខាន ។ ទើបទ្រង់តបគុណដោយបានដោះកងមុក្តាអំពីព្រះសូរង ឱ្យយកទៅប្រទានដល់នាងកិសាគោតមី ក្នុងវេលានោះភ្លាម ។

ព្រះបរមពោធិសត្វ ទ្រង់ស្ដេចឡើងលើប្រាសាទសោយព្រះក្រយាស្ងោយរួចស្រេចហើយ ទ្រង់ស្ដេចចូលទៅកាន់ទីសយនាក្រឡាព្រះបន្ទំ ទ្រង់ផ្ទំលក់ស្កប់ស្កល់ក្នុងពេលបឋមយាម ។ ចំណែកខាងពួកស្រីរបាំ សុទ្ធតែប្រដាប់តាក់តែងរាងកាយ ដោយគ្រឿងអលង្ការគ្រប់បែបយ៉ាង ទាំងរូបឆោមលោមពណ៌ក៏ស្រស់ឆើតឆាយ ហាក់ដូចជាទេពកញ្ញាក្នុងឋានទេវលោក ដែលជាអ្នកស្ទាត់ក្នុងល្បែងច្រៀងរាំជាដើម នាំគ្នាប្រគំតូរ្យតន្ត្រីច្រៀងរាំថ្វាយព្រះមហាសត្វ ។ ស្រីរបាំទាំងនោះ លុះដឹងថា ព្រះមហាបុរសទ្រង់ផ្ទំស្កប់ស៊ប់ហើយ ក៏នាំគ្នាបញ្ឈប់គ្រឿងល្បែង ហើយដេកលក់អស់ទៅ. សំដែងវិប្បការៈផ្សេងៗ មានស្រីខ្លះដេកហាមាត់. ខ្លះដេករបូតសំពត់ចេញពីខ្លួនជាដើម ។ លុះដល់ពេលមជ្ឈិមយាម ព្រះបរមពោធិសត្វទ្រង់តើនឡើងហើយទតឃើញវិប្បការៈនៃស្រីទាំងនោះ ក៏មានព្រះរាជហឫទ័យសង្វេគនឿយណាយយ៉ាងខ្លាំង ព្រោះឃើញទីប្រាសាទទាំងមូល ហាក់ដូចជាពាសពេញទៅដោយសាកសព ដែលគួរ

ឱ្យខ្ពើមរអើមជាទីបំផុត. ព្រះទ័យរបស់ព្រះអង្គទោរទន់ទៅក្នុងភេទបព្វជ្ជារឹងរឹតតែមាំមួនឡើង ហើយប្ដេជ្ញាក្នុងព្រះទ័យថា គួរអាត្មាអញនឹងចេញទៅបួសក្នុងថ្ងៃនេះឱ្យបាន. ទើបទ្រង់ក្រោកចាកទីសយនា ហើយទ្រង់ទៅដាស់ឆន្នអាមាត្យឱ្យទៅយកសេះកណ្ឋកៈអាជានេយ្យមក ។ ឆន្នអាមាត្យទទួលព្រះរាជបញ្ជាហើយ ក៏ទៅប្រដាប់តាក់តែងសេះកណ្ឋកៈដោយគ្រឿងអលង្ការទាំងពួង ដើម្បីនឹងនាំមកថ្វាយព្រះអង្គ ។ សេះកណ្ឋកៈនោះ កាលដែលឆន្នអាមាត្យនោះកំពុងរៀបចំគ្រឿងប្រដាប់ដូច្នោះ ក៏បានដឹងច្បាស់ថា ការរៀបចំប្រដាប់កាយអាត្មាអញម្ដងនេះ មាំមួនប្លែកណាស់ មិនដូចជាកាលដែលទ្រង់ទៅក្រសាលឧទ្យានក្នុងថ្ងៃមុនៗទេ. ព្រះអង្គជាម្ចាស់របស់អាត្មាអញប្រហែលជានឹងចេញទៅទ្រង់ព្រះផ្នួសក្នុងថ្ងៃនេះទេដឹង ? លុះគិតហើយក៏មានចិត្តត្រេកអរ ស្រែកកញ្ជ្រៀវយ៉ាងខ្លាំង ។ ជាអស្ចារ្យចម្លែកពេក សម្រែកសេះនោះ លាន់ឮផ្សាយទៅក្នុងក្រុងទាំងមូល ប៉ុន្តែដោយអំណាចពួកទេវតាបិទខ្ទប់សម្លេងនោះ មិនឱ្យលាន់ឮដល់ជនណាមួយឡើយ ។ ព្រះសិទ្ធត្ថរាជ កាលដែលទ្រង់បង្គាប់ឆន្នអាមាត្យឱ្យទៅនាំសេះកណ្ឋកៈមកថ្វាយ. ព្រះអង្គស្ដេចចូលទៅក្នុងបន្ទប់ជាទីផ្ទំនៃរាហុលមាតា ដោយព្រះបំណងនឹងលើកបីព្រះរាជបុត្រ. ប៉ុន្តែទ្រង់ទតទៅឃើញព្រះនាងពិម្ពាយសោធរា ផ្ទំដាក់ព្រះហស្តគងលើព្រះរាជឱរស ហើយក៏ស្ដេចថយចេញមកវិញ ដោយទ្រង់ព្រះចិន្តាថា បើអាត្មាអញនឹងលើកដៃព្រះនាងទេវីចេញហើយចាប់បីកូនឡើង. ព្រះនាងទេវីមុខជានឹងភ្ញាក់ដឹងខ្លួន ទាំងដំណើររបស់អាត្មាអញសោតទៀត ក៏នឹងអន្តរាយពុំខាន. ណ្ហើយចុះ ចាំអាត្មាអញបានត្រាស់ជាព្រះពុទ្ធហើយ សឹមត្រឡប់មកជួបនឹងកូននេះវិញ ។

ខណៈនោះ ព្រះពោធិសត្វស្ដេចទ្រង់ចុះអំពីផ្ទៃប្រាសាទ ហើយស្ដេចទៅកាន់ទីជិតនៃសេះកណ្ឋកៈ ត្រាស់ថា ម្នាលកណ្ឋកៈ ! ឯងចូរចម្លងអញក្នុងវេលាយប់នេះ អញនឹងបានត្រាស់ជាព្រះពុទ្ធហើយ នឹងចម្លងមនុស្ស-លោកព្រមទាំងទេវលោក អាស្រ័យនឹងឯង ។ លុះត្រាស់ដូច្នេះហើយ ក៏ឡើងគង់ លើខ្នងអស្សពាហន៍ដែលមានមាឌ និងលំអសមជាព្រះទីនាំងឥតមានឆ្លង ។ ឯសេះកណ្ឋកៈនោះ បើនឹងស្រែក ឬនឹងធ្វើសូរនៃជើងកាលណាសម្រែក និងសូរនៃជើងនោះ ក៏លាន់ឮគ្របទូវក្រុងទាំងមូលក្នុងកាលនោះ ប៉ុន្តែទេវតាទាំងឡាយ ខ្ទប់បិទនូវសម្រែកនិងសូរជើងនោះ មិនឱ្យជនណាមួយបានឮឡើយ ហើយនាំគ្នាទ្រជើងសេះដោយផ្ទៃដៃរបស់ខ្លួនៗ គ្រប់វារៈនៃជំហានដែលសេះជាន់ដើរទៅ ។

ខណៈនោះ ព្រះពោធិសត្វទ្រង់ឱ្យឆន្នអាមាត្យជិះកាន់កន្ទុយសេះពីក្រោយ បរចេញទៅដល់ទ្វារធំក្នុងវេលាអធ្រាត្រ តែទ្រង់មិនអាចចេញទៅតាមទ្វារធំបានឡើយ ពីព្រោះព្រះបាទសិរីសុទ្ធោទនៈទ្រង់ចាត់ការឱ្យគេបិទរាំងដោយសន្ទះដ៏មាំ ដើម្បីការពារកុំឱ្យព្រះពោធិសត្វបើកទ្វារក្រុងចេញទៅវេលាណាមួយបាន ។ ព្រោះហេតុនោះ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា បើប្រសិនជាមិនមានអ្នកណាបើកទ្វារនេះទេ អាត្មាអញជិះលើខ្នងសេះនេះហើយតឿ្បតសេះនឹងភ្លៅ មួយអន្លើដោយឆន្នអាមាត្យ ផ្លោះរំលងកំពែងដែលមានកំពស់ ១៨ ហត្ថ ចេញទៅក្នុងថ្ងៃនេះឱ្យត្រាតែបាន ។ ឯឆន្នអាមាត្យក៏គិតថា បើប្រសិនជាមិនមានអ្នកណាបើកទ្វារនេះទេ អាត្មាអញនឹងអញ្ជើញព្រះមហាបុរសឱ្យជិះលើ ក ហើយចាប់ទ្រពោះសេះដោយដៃ លោតផ្លោះរំលងកំពែងនេះចេញទៅឱ្យត្រាតែបាន ។ ចំណែកសេះកណ្ឋកៈក៏គិតថា បើប្រសិនជាមិន

មានអ្នកណាបើកទ្វារនេះឱ្យទេ អាត្មាអញនឹងនាំព្រះពោធិសត្វជាអម្ចាស់អញ ជាមួយនឹងឆន្នអាមាត្យផ្លោះរំលងកំពែងនេះ ចេញទៅវេលាយប់នេះកុំបីឱ្យអាក់ខានឡើយ ។ ប៉ុន្តែទេវតាដែលអាស្រ័យនៅនឹងទ្វារនោះ ក៏បានបើកទ្វារថ្វាយព្រះពោធិសត្វមួយរំពេចនោះឯង ។

ខណៈនោះ មារចិត្តអាក្រក់ដឹងហេតុនោះហើយ ក៏ចុះចាកវសវត្តិទេវលោក មកឋិតនៅឰដ៏អាកាស ពោលឃាត់ដំណើរព្រះពោធិសត្វថា នែសិទ្ធត្ថៈ ! អ្នកកុំចេញទៅបួសឡើយ ដ្បិតនៅតែ ៧ ថ្ងៃទៀតទេ សម្បត្តិចក្រពត្តិនឹងកើតប្រាកដដល់អ្នកហើយ. អ្នកចូរត្រឡប់ទៅវិញទៅ ! ព្រះពោធិសត្វទ្រង់តបថា នែមារ ! យើងដឹងថាសម្បត្តិចក្រពត្តិនឹងកើតប្រាកដដល់យើងដែរ ប៉ុន្តែយើងមិនត្រូវការដោយសម្បត្តិនោះឡើយ ។ ចាប់ដើមតាំងពីថ្ងៃនោះមក មារក៏ចេះតែប្រកិតជាប់តាម គន់រំពៃមើលទោសព្រះពោធិសត្វ ក្រែងមានភ្លាំងភ្លាត់ដោយហេតុណាមួយ ។

មែនពិត ! ព្រះពោធិសត្វទ្រង់បានលះបង់ចោលនូវសម្បត្តិចក្រពត្តិរាជដែលតាំងនៅក្នុងកណ្ដាប់ព្រះហស្តហើយ ដូចជាដុំនៃទឹកមាត់ ឥតមានអាឡោះអាល័យឡើយ ទ្រង់ស្ដេចចេញចាកនគរទៅក្នុងថ្ងៃពេញបូណ៌មី ខែ អាសាឍ ដោយមានគ្រឿងសក្ការៈដ៏ធំអស្ចារ្យ ដែលពួកទេវតាច្រើនណែនណាន់តាន់តាប់ នាំមកបូជាជង្វែអមព្រះរាជដំណើរព្រះអង្គចេញទៅ ។ លុះព្រះអង្គស្ដេចយាងចេញឃ្លាតផុតព្រះនគរបន្តិចទៅ មានព្រះទ័យនឹកភ្នកចង់ទតព្រះនគរវិញ ហើយទ្រង់ព្រះសណ្ឋិតបែរព្រះភក្ត្រទតឆ្ពោះមកព្រះនគរ រួចហើយទ្រង់ញាក់បំបែរសេះកណ្ឋកៈ ឱ្យមានមុខត្រង់ទៅកាន់ផ្លូវ ដែលព្រះអង្គគប្បីយាងទៅ ។ ទីនោះឯងហៅថា **កណ្ឋកនិវត្តចេតិយ** ។ ស្ដេចចេញទៅតែក្នុង

រាត្រីមួយ អស់រយៈផ្លូវចម្ងាយ ៣០ យោជន៍ ទៅដល់ឆ្នេរស្ទឹងអនោមា. ព្រះអង្គឋិតនៅត្រង់ឆ្នេរស្ទឹងនោះហើយ ទ្រង់សួរឆន្នអាមាត្យៗ ក៏ក្រាបបង្គំទូលសព្វគ្រប់ប្រការ. ព្រះអង្គក៏បរសេះឆ្លងទៅត្រើយខាងនាយ ដោយខ្លាចក្រែងព្រះវរបិតាឱ្យមនុស្សមកតាម ។

គ្រានោះ ព្រះពោធិសត្វទ្រង់ចុះចាកខ្នងនៃសេះកណ្ឋកៈ ហើយទ្រង់ស្តេចទៅគង់លើផ្ទៃខ្សាច់ ត្រាស់ហៅឆន្នអាមាត្យមកប្រាប់ថា ម្នាលឆន្នៈស្មើចិត្ត ! ចូរឯងនាំយកគ្រឿងអាភរណៈ និងសេះកណ្ឋកៈ ត្រឡប់ទៅព្រះនគរវិញចុះ អញនឹងបួសនៅទីនេះឯង ។ ឆន្នអាមាត្យក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ! ខ្ញុំព្រះអង្គនឹងបួសជាមួយនឹងព្រះអង្គដែរ ។ ព្រះពោធិសត្វត្រាស់ឃាត់អស់វារៈបីដងថា ឯងនឹងបួសពុំបានទេ. ចូរត្រឡប់ទៅវិញ នាំដំណឹងនេះទៅក្រាបទូលព្រះវរបិតាផង ។ ឆន្នអាមាត្យមិនអាចនឹងទទួចសុំបួសបាន ហើយក៏ថ្វាយបង្គំលាព្រះពោធិសត្វ ដើរប្រទក្សិណរួចហើយ នាំយកគ្រឿងអាភរណៈ និងសេះកណ្ឋកៈចេញទៅ ដោយមានសេចក្តីសោកអាឡោះអាល័យព្រះពោធិសត្វដ៏ក្រៃលែង ។ លុះចេញផុតបន្តិចទៅ សេះនោះឯងក៏បែកហឫទ័យស្លាប់ ដោយសេចក្តីទុក្ខព្រោះការព្រាត់ប្រាសចាកព្រះពោធិសត្វ បានទៅកើតនាឋានតាវត្តិង្សទេវលោក មានឈ្មោះថា **កណ្ឋកទេវបុត្រ** ។

ឆន្នអាមាត្យ បានឃើញសេះកណ្ឋកៈស្លាប់ដូច្នោះហើយ ក៏កើតទុក្ខយំទួញសោកខ្សឹកខ្សួល. លុះបន្ទោបង់នូវសោកបានខ្លះហើយ ក៏ស្រាយយកគ្រឿងប្រដាប់សេះកណ្ឋកៈ វេចជាបង្វេចស្ពាយដើរទៅ. លុះទៅដល់នគរកបិលពស្តុហើយ ក៏នាំប្រដាប់ទាំងនោះ ទៅថ្វាយព្រះបាទសិរីសុទ្ធោទនៈក្រាបទូលតាមបណ្តាំព្រះពោធិសត្វ សព្វគ្រប់ប្រការ ។

ចំណែកខាងកោណ្ឌញ្ញព្រាហ្មណ៍ បានដំណឹងថា ព្រះមហាបុរសចេញទ្រង់ព្រះផ្នួសហើយ ទើបដើរបបួលកូនព្រាហ្មណ៍ទាំង ៧ នាក់ ដែលបានទាយលក្ខណៈព្រះមហាបុរស ។ ឯកូនព្រាហ្មណ៍ ក៏មិនព្រមព្រៀងគ្នាទាំង ៧ នាក់នេះឡើយ. ព្រមតែ ៤ នាក់គឺ ព្រាហ្មណ៍ឈ្មោះភទ្ទិយៈ១ វប្បៈ១ មហានាម ១ អស្សជិ១ រួមទាំងកោណ្ឌញ្ញព្រាហ្មណ៍ផង ត្រូវជា ៥ នាក់ នាំគ្នាចេញទៅបួសតាមព្រះពោធិសត្វ មានឈ្មោះថា **បញ្ចវគ្គិយភិក្ខុ** ក្នុងកាលនោះឯង ។

ខណៈនោះ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា កេសារបស់អាត្មាអញមិនសមគួរដល់សមណភេទទេ គួរនឹងកាត់កេសានេះចេញ. ក៏ស្រាប់តែព្រះខ័នកែវជាទិព្វ ធ្លាក់ចុះមកថ្វាយព្រះពោធិសត្វ. ព្រះអង្គទ្រង់កាត់ព្រះកេសាទុកឱ្យនៅប្រវែងត្រឹមតែ ២ ធ្នាប់ ព្រះកេសានោះក៏រំលជាទក្ខិណាវដ្ដ រាបទៅនឹងព្រះសិរៈរបស់ព្រះអង្គ ។ ព្រះពោធិសត្វទ្រង់ចាប់ព្រះមោលី(១) ដែលកាត់ហើយបោះទៅឯអាកាសអធិដ្ឋានថា បើអាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដមែន សូមឱ្យមោលីនេះ ប្រតិស្ឋានតាំងនៅឰដ៏អាកាស. បើមិនបានត្រាស់ទេ សូមឱ្យមោលីនេះធ្លាក់មកលើផែនដីវិញចុះ. ព្រះមោលីនោះក៏អណ្ដែតទៅប្រតិស្ឋានឯអាកាស កំពស់ពីផែនដីប្រហែលមួយយោជន៍ ។ ខណៈនោះ សក្កទេវរាជបានទទួលដាក់ក្នុងប្រអប់កែវ នាំយកទៅដំកល់ទុកក្នុងចូឡាមណិចេតិយនាឋានត្រៃត្រឹង្សទេវលោក ។

លំដាប់នោះ ព្រះបរមពោធិសត្វទ្រង់ព្រះតម្រិះថា កាសិកពស្ត្ររបស់អាត្មាអញនេះពុំសមគួរដល់សមណភេទឡើយ ។ ខណៈនោះ ឃដិការមហាព្រហ្មជាសម្លាញ់ចាស់របស់ព្រះពោធិសត្វ តាំងពីក្នុងសាសនានៃព្រះពុទ្ធកស្សបៈ

១-ផ្នួងព្រះកេសា. ផ្នួងសក់ ។

គិតថា ថ្ងៃនេះ ព្រះសិទ្ធត្ថរាជពោធិសត្វជាសម្លាញ់អញ ចេញបួសហើយតើ ! អាត្មាអញត្រូវយកគ្រឿងបរិក្ខារទៅថ្វាយ ។ លុះគិតហើយ ព្រហ្មនោះក៏យកសមណបរិក្ខារ ៨ មុខមកថ្វាយក្នុងខណៈនោះភ្លាម ។ សមណបរិក្ខារនោះគឺ ចីវរ ៣ (ស្បង់១ ចីពរ១ សង្ឃាដី១) បាត្រដី១ កាំបិតកោរ១ បំពង់ម្ជុល១ វត្ថពន្ធចង្កេះ១ តម្រងទឹក១ ទាំង ៨ មុខនេះហៅថា **អដ្ឋបរិក្ខារ** [១] ។

ព្រះមហាបុរសទ្រង់ទទួលអដ្ឋបរិក្ខារនោះហើយ ឥតមានបុគ្គលណាមួយពន្យល់ព្រះអង្គថា "ត្រូវស្លៀកយ៉ាងនេះ ត្រូវដណ្តប់យ៉ាងនេះ" ដូច្នេះឡើយ គឺកុសលដែលព្រះអង្គធ្លាប់សន្សំទុកមក ដោយព្រះអង្គធ្លាប់បានបួសអស់សែននៃជាតិជាអនេក មកពន្យល់ព្រះអង្គ ឱ្យបានជ្រាបក្នុងការស្លៀកដណ្តប់. ព្រះអង្គក៏បានស្លៀកស្បង់ ហើយក្រវាត់វត្ថពន្ធចង្កេះពីលើស្បង់នោះ ហើយដណ្តប់ចីវរឆៀងព្រះអង្សាម្ខាង ហើយពាក់សង្ឃាដីពាតពីលើ ហើយទ្រង់ច្រកបាត្រដីក្នុងស្លោក ហើយស្ពាយលើព្រះអង្សា ទ្រង់កាន់ភេទបព្វជ្ជាដ៏ឧត្តម ហើយទ្រង់បោះនូវសាដកទាំងគូទៅឯអាកាស [២] ។ ឃដិកាមហាព្រហ្មក៏បានទទួលយកសំពត់ទាំងគូនោះ ទៅដំកល់ទុកក្នុង **ទុស្សចេតិយ** ឯឋានព្រហ្មលោក ។ កាលដែលព្រះមហាសត្វ ស្តេចចេញទ្រង់ព្រះផ្នួសនោះ នៅថ្ងៃ **ព្រហស្បតិ៍ ១៥**កើត **ខែអាសាឍ ឆ្នាំមមែ** នៅវេលា **បច្ឆិមយាម** (ពាក់កណ្តាលអធ្រាត្រ) ក្នុងព្រះជន្មគម្រប់ **២៩**ព្រះវស្សា ។ ចប់មហាភិនិក្ខមនកថា

១-អដ្ឋបរិក្ខារនេះ កើតស្រេចស្រាប់ក្នុងផ្កាឈូកតាំងពីក្នុងខាងដើមនៃភទ្ទកប្បនេះ ដែលពួកព្រហ្មបានយកទៅទុកឯព្រហ្មលោក ។

២-បាលីក្នុងអដ្ឋកថាធម្មចក្ក ថា មហាបុរិសោ អដ្ឋបរិក្ខារេ គហេត្វា ឯវំ និវាសេតព្វំ ឯវំ បារុបិតព្វន្តិ កេនចិ អនានុសិដ្ឋោ អនេកជាតិ សតសហស្សប្បត្តិ តេន អត្តនោ បព្វជ្ជា ចិណ្ណេនេវ សិក្ខាបិយមានោ ឯកំ កាសាវំ និវាសេត្វា តស្ស បរិកាយពន្ធនំ ពន្ធិត្វា ឯកំ ឧត្តរាសង្គំ ករិត្វា មត្តិកាបត្តំ ថវិកាយ បក្ខិបិត្វា អសេអាលគ្គេត្វា ឧត្តមំ បព្វជ្ជា គណ្ហិត្វា វំ សាដកយុគំ អាកាសេ ខិបិ ។ សេចក្តីប្រែដូចខាងលើ ។

## ៨. ពិម្ពិសារបដិញ្ញាគថា

លុះព្រះពោធិសត្វទ្រង់ភេទបព្វជ្ជារួចហើយ ក៏ស្តេចយាងទៅគង់ក្នុងអនុប្បិយម្ពវ៉ែនក្នុងប្រទេសនោះ ទ្រង់មិនសោយអាហារអស់ ៧ថ្ងៃ ទ្រង់ញ៉ាំងកាលឱ្យប្រព្រឹត្តទៅ ដោយសេចក្តីសុខក្នុងបព្វជ្ជា ។ លុះដល់ថ្ងៃទី ៨ ព្រះអង្គទ្រង់ប្រដាប់ដោយបាត្រនិងចីវរ ស្តេចចរសំដៅទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ។ មនុស្សទាំងឡាយក្នុងក្រុងទាំងមូល បានឃើញរូបសម្បត្តិនៃព្រះពោធិសត្វ ដែលល្អសមរម្យព្រមទាំងសម្បៀកបំពាក់ចម្លែកដូច្នោះ ក៏ភ្ញាក់ផ្អើលជ្រួលជ្រើម ដោយពុំស្គាល់ថាជាមនុស្សអ្វី ។

ចំណែកខាងរាជបុរស បានឃើញព្រះពោធិសត្វហើយ ក៏ទៅក្រាបបង្គំទូលព្រះបាទពិម្ពិសារថា បពិត្រព្រះសម្មតិទេព ! មានមនុស្សម្នាក់រូបល្អចម្លែកណាស់ កំពុងដើរបិណ្ឌបាតក្នុងក្រុង. ខ្ញុំព្រះអង្គពុំស្គាល់ថាជាទេវតា ឬមនុស្សជានាគឬគ្រុឌ ឬជាអ្វីឡើយ ។ ព្រះបាទពិម្ពិសារ ក៏ទ្រង់បើកសីហបញ្ជរ (បង្អួច) ទតទៅឃើញព្រះមហាបុរស ក៏មានសេចក្តីស្ងើចអស្ចារ្យក្នុងព្រះហឫទ័យ ហើយទ្រង់ត្រាស់បង្គាប់ទៅរាជបុរសថា អ្នកទាំងឡាយ ! ចូរទៅឃ្លាំមើលឱ្យដឹងថា បើជាអមនុស្ស[១] វេលាចេញពីក្រុងទៅ គង់តែនឹងបាត់ បើជាទេវតាគង់នឹងហោះទៅតាមអាកាស. បើជានាគវិញ គង់នឹងមុជជ្រែកចុះទៅក្នុងផែនដី. បើជាមនុស្ស គង់នឹងបរិភោគនូវអាហារដែលខ្លួនបាននោះឯង ។

ព្រះមហាបុរស មានឥន្ទ្រិយសង្រួមស្រគត់ស្រគំដោយប្រពៃ ស្តេចចរបិណ្ឌបាតតាមលំដាប់. លុះបានមិស្សកភត្ត (ភត្តដែលលាយច្របូកច្របល់ដោយរបស់ច្រើនមុខ) ល្មមមួយចំអែតហើយ ទ្រង់ស្តេចយាងចេញចាកក្រុង ទៅ

១-ពាក្យអមនុស្សក្នុងទីនេះ សំដៅយកបិសាច ឬប្រេតជាដើម ។

គង់ក្នុងញកបណ្ឌវបព៌ត បែរព្រះភ័ក្ត្រទៅទិសខាងកើត ប្រារព្ធនឹងសោយនូវអាហារ ទ្រង់មានព្រះរាជហឫទ័យក្រាញចំពោះអាហារ ដែលច្របូកច្របល់ក្នុងបាត្រដី ទៅជាបដិកូលគួរឱ្យឆ្អើម រកកលសោយពុំកើត ព្រោះព្រះអង្គពុំធ្លាប់បានទតឃើញអាហារបែបនេះសោះឡើយ ហើយទ្រង់ទូន្មានព្រះអង្គដោយព្រះអង្គឯងថា "នែសិទ្ធត្ថ ! អ្នកឯងកើតក្នុងត្រកូលខ្ពង់ខ្ពស់ ដែលសម្បូរដោយភោជនទិងទឹកមានរសជាតិប្រសើរថ្លៃថ្លាណាស់ ឥឡូវនេះ អ្នកឯងបានអាហារបែបនេះ ជាការគួរដល់អ្នកឯងហើយ. អ្នកឯងត្រូវបរិភោគទៅកុំខ្ពើម !" ។ លុះទូន្មានព្រះអង្គយ៉ាងនេះហើយ ក៏ខំប្រឹងសោយអាហារនោះទៅ ។

រាជបុរសទាំងឡាយដែលតាមមើលនោះ លុះបានឃើញព្រះពោធិសត្វកំពុងសោយភត្តាហារក្នុងញកភ្នំ ក៏ត្រឡប់ទៅក្រាបបង្គំទូលព្រះបាទពិម្ពិសារវិញ តាមដំណើរសព្វគ្រប់ប្រការ ។ ព្រះរាជា បានទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទ្រង់ស្ដេចចេញទៅកាន់សំណាក់ព្រះពោធិសត្វ ឃើញព្រះអង្គមានឥរិយាបថស្រគត់ស្រគំល្អ ក៏កើតសេចក្ដីជ្រះថ្លា ទ្រង់សាកសួរអំពីជាតិត្រកូលរបស់ព្រះអង្គ. ព្រះពោធិសត្វក៏ថ្វាយព្រះពរតាមដំណើរសព្វគ្រប់ប្រការ ។ ព្រះបាទពិម្ពិសារជ្រាបហើយ ក៏ប្រគល់ឥស្សរិយយសថ្វាយព្រះពោធិសត្វៗ ត្រាស់ថា បពិត្រមហារាជ ! អាត្មាឥតមានត្រូវការឥស្សរិយយសអ្វីឡើយ. ដែលអាត្មាភាពចេញមកបួសនេះ ដើម្បីប្រាថ្នានូវបរមាភិសម្ពោធិញ្ញាណតែមួយយ៉ាងប៉ុណ្ណោះ ។ ព្រះមហាសត្តទ្រង់បានសំដែងពីទោសនៃកាមជាអនេកប្បការថ្វាយព្រះរាជា ។ លុះព្រះបាទពិម្ពិសារបានទ្រង់ព្រះសណ្ដាប់ធម្មកថានោះសព្វគ្រប់ហើយ ក៏ទូលសុំបេ្តជ្ញានឹងព្រះពោធិសត្វថា កាលណាបើព្រះអង្គបានត្រាស់ជាព្រះពុទ្ធពិតប្រាកដហើយ សូមទ្រង់ស្ដេចយាងមកកាន់ដែនរបស់ខ្ញុំជា

មុន ។ ព្រះពោធិសត្វបានថ្វាយបង្គំចំពោះព្រះបាទពិម្ពិសារហើយ ទ្រង់ស្ដេចចេញចាកភ្នំបណ្ឌវៈ ស្ដេចត្រាច់ចរទៅកាន់ចារិកជនបទតាមលំដាប់ ក៏បានចូលទៅកាន់សំណាក់អាឡារតាបសកាឡាមគោត្រ និងឧទកតាបសរាមបុត្រ ទ្រង់ចំរើនបានសមាបត្តិហើយ ទើបព្រះអង្គសួររកធម៌ពិសេសតទៅទៀត ។ តាបសទាំងនោះ ទញ់ទាល់ ពុំអាចនឹងពន្យល់តទៅទៀតបានឡើយ ។ ព្រះពោធិសត្វទ្រង់សន្និដ្ឋានថា "ធម៌នេះមិនមែនជាផ្លូវនាំឱ្យបានត្រាស់ដឹងទេ" ទើបព្រះអង្គចេញពីសំណាក់នៃតាបសទាំងពីររូបនោះ ចូលទៅកាន់សេនានិគមក្នុងឧរុវេលប្រទេស ទ្រង់ព្រះតម្រិះថា ភូមិភាគនេះជាប្រទេសគួររីករាយណាស់តើ ! ទើបទ្រង់សំរេចឥរិយាបថតាំងទុកនូវមហាបធាន (សេចក្ដីព្យាយាមធំ) ក្នុងទីនោះឯង ។

ចប់ពិម្ពិសារប្បដិញ្ញាកថា

## ៩. ទុក្ករកិរិយាកថា

សម័យនោះ បព្វជិតទាំង ៥ រូប មានកោណ្ឌញ្ញព្រាហ្មណ៍ជាប្រធាន កាលដែលបានទៅទាយលក្ខណៈព្រះមហាបុរសហើយ បបួលគ្នាចេញទៅបួសនោះ ក៏បានត្រាច់បិណ្ឌបាតក្នុងស្រុកនិគមនិងរាជធានី ជាលំដាប់ដរាបដល់បានទៅជួបនឹងព្រះពោធិសត្វ នៅក្នុងសេនានិគមនោះ ។ បញ្ចវគ្គិយភិក្ខុនោះបំរើព្រះមហាសត្វដែលកំពុងធ្វើទុក្ករកិរិយារអស់ ៦វស្សានោះ ដោយទឹកសង្ឃឹមថា ព្រះសិទ្ធត្ថនឹងបានត្រាស់ជាព្រះពុទ្ធក្នុងថ្ងៃនេះ ឬថ្ងៃនោះពុំខាន ។ ព្រះពោធិសត្វខំធ្វើមហាបធានកិរិយា អស់កាលជិត ៦វស្សាហើយ ក៏នៅតែមិនទាន់បានត្រាស់ ព្រះអង្គក៏បន្ថយអាហារជាលំដាប់ៗ ដរាបដល់តតសោយសោះ ។

ទេវតាក៏នាំយកឱជាទិព្វមកដាក់ក្នុងរណ្ដៅនៃរោម. ដោយហេតុដែលព្រះអង្គអត់អាហារមិនសោយសោះនោះ ព្រះកាយដែលមានសម្បុរដូចជាមាស ក៏ត្រឡប់ជាមានសម្បុរខ្មៅជាំទៅវិញ ទាំងមហាបុរិសលក្ខណៈ ៣២ ប្រការ ក៏ទៅជាស្រអាប់កំបាំងបាត់មិនប្រាកដដែរ. ព្រះអង្គត្រូវទុក្ខវេទនាគ្របសង្កត់យ៉ាងខ្លាំង ធ្វើឱ្យបាត់ព្រះស្មារតីដួលផ្ងស្តូកស្តឹងក្នុងទីចង្ក្រម ។ គ្រានោះ ពួកទេវតាខ្លះប្រឹក្សាគ្នាថា ព្រះសមណគោតមធ្វើមរណកាលទៅហើយ ។ ពួកទេវតាខ្លះថា ព្រះសមណគោតមរស់នៅឡើយទេ បើមិនទាន់បានសម្រេចព្រះអរហត្ត ។ ពួកទេវតាណាដែលមានសេចក្ដីយល់ថា ព្រះពោធិសត្វធ្វើមរណកាលទៅហើយ ពួកទេវតានោះ ក៏ហោះទៅទូលព្រះបាទសិរីសុទ្ធោទនៈៗ ទ្រង់ត្រាស់តបថា ខ្ញុំពុំជឿទេ ព្រោះកូនខ្ញុំ បើមិនទាន់បានត្រាស់ជាព្រះពុទ្ធទេ នឹងមិនធ្វើមរណកាលឡើយ ។ ចុះព្រោះហេតុអ្វីបានជាព្រះរាជាមិនទ្រង់ជឿ ? ព្រោះព្រះអង្គបានឃើញបាដិហារ្យអស្ចារ្យ ក្នុងថ្ងៃដែលបានថ្វាយបង្គំទេវិលតាបសម្ដង, ត្រង់ខាងក្រោមជម្ពូព្រឹក្សនៅថ្ងៃច្រត់ព្រះនង្គ័លនោះម្ដង ។

ក្នុងខណៈដែលព្រះបរមពោធិសត្វកំពុងធ្វើព្យាយាម ដរាបដល់ដួលផ្ងស្តូកស្តឹងលើផែនដីនោះ សក្កទេវរាជយកពិណមានខ្សែ ៣ មកដេញថ្វាយ, បណ្ដាខ្សែទាំង ៣ នោះ ខ្សែ១រឹតតឹងណាស់ក៏ដាច់ទៅ, ខ្សែ១រឹតធូរណាស់មានសម្លេងមិនពិរោះ, ខ្សែ១រឹតយ៉ាងកណ្ដាលល្មម សម្លេងក៏ពិរោះស្រួលស្ដាប់ ។ ខណៈនោះ ព្រះអង្គមានព្រះស្មារតីឡើង បានឮសម្លេងពិណនោះទ្រង់ពិចារណាថា សេចក្ដីព្យាយាមរបស់អាត្មាអញនេះតឹងហួសកម្រិតណាស់នេះមិនមែនជាផ្លូវនាំឱ្យបានត្រាស់ដឹងទេ. លុះទ្រង់ពិចារណាឃើញដូច្នោះហើយ ក៏បន្ថយព្យាយាមចុះមកតាំងនៅជាកណ្ដាល មិនតឹងមិនធូរពេក

ហើយទ្រង់ស្តេចត្រាច់ចរទៅបិណ្ឌបាត សោយអាហារ តាមធម្មតាវិញ. ឯមហាបុរិសលក្ខណៈទាំង ៣២ ប្រការរបស់ព្រះអង្គ ក៏បានតាំងនៅជាប្រក្រតីដដែលឡើងវិញ ទាំងព្រះកាយសោត ក៏មានសម្បុរស្រស់បស់ល្អ ពេញលេញឡើងវិញដែរ ។

ចំណែកខាងបញ្ចវគ្គិយភិក្ខុ បានឃើញព្រះមហាបុរសបន្ធូរបន្ថយព្យាយាមវិញ ក៏គិតគ្នាថា ព្រះសិទ្ធត្ថនេះ សូម្បីកំពុងធ្វើទុក្ករកិរិយាអស់កាលជិត ៦ វស្សា មិនអាចចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណបាន ចំណង់បើឥឡូវនេះត្រឡប់ដើរបិណ្ឌបាតសោយអាហារវិញហើយ អង្កាល់ណានឹងបានត្រាស់ដឹង ? ណ្ហើយ ប្រយោជន៍អ្វីពួកយើងនឹងនៅបំរើតទៅទៀត ។ បញ្ចវគ្គិយភិក្ខុទាំងនោះ ក៏យកបាត្រនិងចីវររបស់ខ្លួន ដើរចោលព្រះមហាបុរស ទៅកាន់ផ្លូវចម្ងាយ ១៨ យោជន៍ បបួលគ្នាទៅនៅក្នុងព្រៃឥសិបតនមិគទាយវ័នជិតក្រុងពារាណសី តាមគាប់អធ្យាស្រ័យរបស់ខ្លួន ។

ចប់ ទុក្ករកិរិយាកថា

## ១០-សុជាតាកថា

ក្នុងសម័យនោះ មាននាងទារិកាម្នាក់ឈ្មោះ **សុជាតា** ជាធីតានៃសេនកុដុម្ពិក៍ នៅក្នុងសេនានិគមក្នុងឧរុវេលប្រទេស. នាងមានវ័យចំរើនឡើង បានទៅបន់ទេវតានៅដើមជ្រៃមួយដើមថា បើខ្ញុំបានប្តីមានជាតិស្មើគ្នាហើយបានកូនប្រុសជាដំបូង ដូចសេចក្តីប្រាថ្នារបស់ខ្ញុំនេះពិតមែន ខ្ញុំនឹងធ្វើគ្រឿងពលិកម្ម មានតម្លៃមួយសែនកហាបណៈថ្វាយដល់លោករាល់ៗឆ្នាំ ។ លុះចំណោរកាលតមក សេចក្តីប្រាថ្នារបស់នាងក៏បានសំរេចដូចបំណង ។

កាលដែលព្រះមហាសត្ត កំពុងធ្វើទុក្ករកិរិយាអស់ ៦ វស្សានោះ នាងសុជាតា មានបំណងនឹងធ្វើពលិកម្មដល់ទេវតាក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ, នាងបង្គាប់ឱ្យមនុស្សនាំមេគោ ១ ពាន់ទៅលែងក្នុងព្រៃឈើអែម. លុះដល់វេលាល្ងាច នាងឱ្យយកភាជន៍មកត្រងទឹកដោះគោអំពីមេគោ៥០០ យកទៅឱ្យមេគោ៥០០ ដែលមិនទាន់បានរីតទឹកដោះនោះផឹក ។ នាងសុជាតាឱ្យបែងភាគចែកជាពាក់កណ្ដាល១ យ៉ាងនេះ ដរាបដល់នៅសល់តែមេគោ ៨, បានជានាងសុជាតាធ្វើដូច្នេះ ដើម្បីឱ្យទឹកដោះនោះ មានរសផ្អែមល្អ ។

នាងសុជាតាគិតថា នៅវេលាព្រឹកស្អែកនេះ ជាថ្ងៃពេញបូណ៌មីខែពិសាខ អាត្មាអញនឹងត្រូវធ្វើពលិកម្មដល់ទេវតាដែលនៅរក្សាដើមជ្រៃ ។ លុះព្រឹកឡើង នាងក៏ឱ្យរីតទឹកដោះមេគោទាំង ៨, គេគ្រាន់តែបង្អោនភាជន៍ចូលទៅជិតកន្សោមដោះមេគោ, ទឹកដោះក៏ហូរចុះមកឯង តាមធម្មតារបស់ខ្លួន។ នាងសុជាតាបានឃើញហេតុជាអស្ចារ្យដូច្នោះ ក៏កាន់ភាជន៍ទឹកដោះនោះដោយខ្លួនឯង ទៅចាក់ដាក់ក្នុងឆ្នាំងថ្មី, បង្កាត់ភ្លើងដោយដៃឯង ប្រារព្ធនឹងចំអិនមធុបាយាស ។ មធុបាយាស ដែលនាងកំពុងចំអិននោះ មានពពុះវិលជាទក្ខិណាវ័ត្តិប្រព្រឹត្តទៅជុំវិញ សូម្បីតែមួយតំណក់ ក៏មិនបានហៀរស្រក់ធ្លាក់ទៅខាងក្រៅមាត់ឆ្នាំងឡើយ ទាំងផ្សែងភ្លើងសោត សូម្បីបន្តិចបន្តួចក៏គ្មានហុយឡើងអំពីជើងក្រានដែរ ។

សម័យនោះ លោកបាលមហារាជទាំង ៤ ចុះមកជួយរក្សាជើងក្រាន, មហាព្រហ្មយកស្វេតច្ឆត្រមកបើកបាំង, ឯសក្កទេវរាជមកជួយថែភ្លើង ។ ចំណែកខាងទេវតាទាំងឡាយ ក៏នាំយកឱជារសទិព្វ មកដាក់ក្នុងមធុបាយាសដោយអានុភាពនៃខ្លួន១ ។ ក្នុងថ្ងៃនោះឯង នាងសុជាតាបានឃើញហេតុ

អស្ចារ្យជាអនេក ប្រាកដដល់ខ្លួនដូច្នោះ ក៏ហៅទាសីឈ្មោះ **បុណ្ណា** មកប្រាប់ថា នែបុណ្ណាអើយ ! ថ្ងៃនេះពួកទេវតាមានចិត្តជ្រះថ្លានឹងយើងពេកណាស់. ហេតុអស្ចារ្យចម្លែកយ៉ាងនេះ អញមិនធ្លាប់ដែលបានឃើញសោះឡើយ. ចូរឯងប្រញាប់ប្រញាល់ទៅបោសសំអាតក្រោមដើមជ្រៃ ជាទីលំនៅនៃទេវតាឱ្យបានស្អាតបាត ។ នាងបុណ្ណាទាសី ក៏ទទួលតាមបង្គាប់របស់នាងសុជាតាដោយសព្វគ្រប់ ។

នៅក្នុងបច្ចូសសម័យថ្ងៃ ១៥ កើតខែពិសាខនោះ, ព្រះមហាបុរសទ្រង់ឃើញមហាសុបិន ៥ យ៉ាង. ឯមហាសុបិនទាំង ៥ យ៉ាងនោះគឺ :

ព្រះអង្គទ្រង់ឃើញថា ព្រះអង្គផ្ទំផ្ងារផ្ទាល់លើមហាប្រឹថពី បើកព្រះនេត្រទាំងពីរទតឃើញនូវពន្លឺភ្លឺដរាបដល់ភវគ្គព្រហ្ម. ភ្នំហេមពាន្ត ជាខ្នើយរងព្រះសិរ. ព្រះហស្តខាងឆ្វេង សណ្ដូកចុះទៅក្នុងមហាសមុទ្រខាងទិសបូព៌, ព្រះហស្តខាងស្ដាំ សណ្ដូកចុះទៅក្នុងមហាសមុទ្រខាងទិសបស្ចិម, ព្រះបាទទាំងគូ សណ្ដូកចុះទៅក្នុងមហាសមុទ្រខាងទិសទក្សិណ. នេះជា មហាសុបិនទី ១ ។

ទ្រង់ឃើញស្មៅចិញ្ចៀន ដុះលេចចេញពីព្រះនាភី(ផ្ចិត) ឡើងទៅដរាបទល់នឹងអាកាស. នេះជា មហាសុបិនទី ២ ។

ទ្រង់ឃើញដង្កូវទាំងឡាយមានខ្លួនសុទ្ធតែស១, ក្បាលខ្មៅ១ វារឡើងពីចុងព្រះបាទា ដរាបដល់ព្រះជង្ឃា(ស្មង). នេះជា មហាសុបិនទី ៣ ។

ទ្រង់ឃើញសត្វបក្សី ៤ ពួក មានវណ្ណៈផ្សេង១ពីគ្នា ហើរពីទិសទាំង ៤ មកក្រាបទៀបព្រះបាទា ហើយត្រឡប់ទៅជាមានវណ្ណៈសទាំងអស់. នេះជា មហាសុបិនទី ៤ ។

ទ្រង់ឃើញថា ព្រះអង្គស្ដេចយាងចង្ក្រមលើភ្នំលាមកដ៏ធំ តែព្រះបាទទាំង២ ឥតមានប្រឡាក់ដោយលាមកនោះឡើយ. នេះជា មហាសុបិនទី ៥ ។

ព្រះមហាបុរស ទ្រង់ឃើញសុបិនទាំង ៥ នេះហើយ ព្រះអង្គក៏តើនចាកទីសយនា ហើយទ្រង់សន្និដ្ឋានក្នុងព្រះហឫទ័យថា អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធក្នុងថ្ងៃ ១៥ កើតខែពិសាខនេះ ដោយឥតសង្ស័យឡើយ. ហើយទ្រង់ព្យាករដោយព្រះអង្គឯងថា ការដេកលើផែនដី ជាបុព្វនិមិត្តដែលនឹងបាននូវអនុត្តរសម្មាសម្ពោធិញ្ញាណ ។ ភ្នំហេមពាន្តជាខ្នើយរងព្រះសិរនោះ ជាបុព្វនិមិត្តដែលនឹងបាននូវខ្នើយគឺសព្វញ្ញុតញ្ញាណ ។ ការសណ្ដូកដៃនិងជើងចុះទៅក្នុងមហាសមុទ្រនោះ ជាបុព្វនិមិត្តដែលនឹងត្រូវសំដែងធម្មចក្កដល់ទេវ-តានិងមនុស្ស ។ ការដេកផ្ងារផ្ទាល់លើមហាប្រឹថពីនោះ ជាបុព្វនិមិត្តដែលនឹងត្រូវធ្វើសត្វដែលមានមុខផ្កាប់ចុះឱ្យផ្ងារឡើង ។ ការដេកបើកភ្នែកនោះ ជាបុព្វនិមិត្តដែលនឹងឱ្យបាននូវទិព្វចក្ខុ ។ ការឃើញនូវពន្លឺភ្លឺដរាបដល់ភវគ្គព្រហ្មនោះ ជាបុព្វនិមិត្តដែលនឹងឱ្យបាននូវអនាវរណញ្ញាណ ។ ការឃើញស្មៅចិញ្ចៀនដុះចេញអំពីផ្ចិតនោះ ជាបុព្វនិមិត្តដែលនឹងត្រូវសំដែងនូវអដ្ឋង្គិក-មគ្គ ។ ការឃើញពួកដង្កូវមានខ្លួនសុទ្ធតែស១ ក្បាលខ្មៅ១វារឡើងពីចុងជើងដរាបដល់ស្មងនោះ ជាបុព្វនិមិត្តដែលនឹងឱ្យបរិស័ទទាំង ៤ បានដល់នូវព្រះត្រៃសរណគមន៍ស្មើដោយជីវិត ។ ការឃើញសត្វបក្សី ៤ ពួកហើរចេញមកអំពីទិសទាំង ៤ នោះ ជាបុព្វនិមិត្តនៃត្រកូលទាំង ៤ នឹងចេញបួសប្រព្រឹត្តតាមធម៌និងវិន័យ ។ ការដើរចង្ក្រមលើភ្នំលាមកនោះ ជាបុព្វនិមិត្តនៃចតុប្បច្ច័យដែលកើតឡើងដល់អាត្មាអញ ប៉ុន្តែចិត្តរបស់អាត្មាអញ ឥតជាប់ជំពាក់ក្នុងបច្ច័យទាំងនោះឡើយ ។

លុះរាត្រីនោះកន្លងទៅហើយ ព្រះពោធិសត្វទ្រង់ជម្រះព្រះសរីរកាយស្រេចហើយ ទ្រង់ស្ដេចទៅគង់នៅនាដើមជ្រៃ ដើម្បីរង់ចាំភិក្ខាចារវេលា ។ នៅខាងក្រោមដើមជ្រៃទាំងមូលនោះឯង ក៏មានពន្លឺរុងរឿងដោយរស្មីរបស់ព្រះអង្គ ។ គ្រានោះ នាងបុណ្ណទាសី ដើរទៅបានឃើញព្រះពោធិសត្វកំពុងគង់ទតលោកធាតុ បែរព្រះភក្ត្រទៅទិសខាងកើត មានរស្មីផ្សាយចេញអំពីព្រះសរីរៈមានពណ៌ដូចជាមាស ក៏គិតថា ថ្ងៃនេះ ប្រហែលជាទេវតាយើងចុះអំពីដើមជ្រៃ មកអង្គុយរង់ចាំទទួលគ្រឿងពលិកម្មដោយដៃខ្លួនឯងទេដឹង ? នាងក៏មានចិត្តត្រេកអរ ប្រញាប់ប្រញាល់ ត្រឡប់មកជំរាបហេតុនោះ ដល់នាងសុជាតាវិញ ។

នាងសុជាតា បានស្ដាប់ពាក្យនាងបុណ្ណទាសីនោះហើយ ក៏មានចិត្តត្រេកអរស្រដីតបទៅថា បើពិតដូច្នោះមែន. តាំងពីថ្ងៃនេះទៅ ឯងចូរឋិតនៅក្នុងទីជាធីតាច្បងនៃអញ ។ លុះថាដូច្នេះហើយ ក៏ឱ្យគ្រឿងអលង្ការគ្រប់បែបដល់នាងបុណ្ណទាសីតាមសមគួរ ។ នាងសុជាតាបង្គាប់នាងបុណ្ណទាសីឱ្យយកភាជន៍មាសមានតម្លៃ ១សែន មកដាក់មធុបាយាស ១ទាំងអស់ ក៏ស្រាប់តែត្រឡប់មកឋិតនៅក្នុងភាជន៍មាស ពេញដោយខ្លួនឯងមួយរំពេច ហាក់ដូចជាទឹកដែលហូរចុះចាកស្លឹកឈូក ។ នាងសុជាតាយកភាជន៍ដទៃមកគ្របភាជន៍នោះ ហើយវេចដោយសំពត់ស. នាងប្រដាប់តាក់តែងអត្តភាពដោយគ្រឿងអលង្ការទាំងពួងរួចហើយ ក៏លើកភាជន៍នោះទូលលើក្បាលនៃខ្លួន ដើរទៅដល់ទីជិតដើមជ្រៃ ក្រឡេកទៅឃើញព្រះពោធិសត្វ កំពុងគង់នៅខាងក្រោមដើមជ្រៃនោះ នាងមានសោមនស្សកាន់តែខ្លាំងឡើង ដោយសំគាល់ថាជាទេវតា ទើបលើកមធុបាយាសបង្អោនចូលទៅថ្វាយ ។ បាត្រដីដែលឃដិកា

មហាព្រហ្មថ្វាយនោះ ក៏បាត់ទៅ មិនប្រាកដក្នុងខណៈនោះ ។ ព្រះពោធិសត្វទ្រង់ងាករកបាត្រនឹងទទួល មិនឃើញ, ទើបនាងសុជាតាកំណត់ដឹងអាការៈនៃព្រះពោធិសត្វហើយ នាងក៏ថ្វាយទាំងភាជន៍មាស ដោយពាក្យថា សេចក្ដីប្រាថ្នារបស់ខ្ញុំម្ចាស់សំរេចហើយ ខ្ញុំម្ចាស់ថ្វាយមធុបាយាសព្រមទាំងភាជន៍នេះដល់លោកម្ចាស់ ។ រួចហើយ នាងក៏ថ្វាយបង្គំលា ដើរចេញមកកាន់និវេសនដ្ឋានរបស់នាងវិញ ។

គ្រានោះ ចំណែកខាងព្រះពោធិសត្វទ្រង់ក្រោកចាកអាសនៈ ស្ដេចប្រទក្សិណដើមជ្រៃរួច ទ្រង់កាន់ភាជន៍នោះ ស្ដេចយាងទៅឆ្នេរស្ទឹងនេរញ្ជរាដល់ហើយទ្រង់ដាក់ភាជន៍ទៀបឆ្នេរស្ទឹង, ទើបទ្រង់ស្ដេចយាងចុះស្រង់ទឹកក្នុងស្ទឹង, លុះស្រង់ស្រេចហើយ ទ្រង់ស្លៀកដណ្ដប់ចីវរគង់បែរព្រះភក្ត្រទៅខាងបុរត្ថិមទិស, ព្រះអង្គពូតមធុបាយាសជាពំនូត១, ក្នុងពំនូតនីមួយ១ប្រមាណប៉ុនគ្រាប់ក្នុងនៃផ្លែត្នោត បានចំនួន ៤៩ ពំនូត ហើយទ្រង់សោយទាំងអស់ឥតមានសេសសល់ឡើយ ។

មធុបាយាសនេះហើយ ជាអាហាររបស់ព្រះពោធិសត្វដែលបានត្រាស់ជាព្រះពុទ្ធហើយ នាំឱ្យមានព្រះកាយពល ទ្រង់គង់នៅត្រង់ពោធិមណ្ឌានអស់ ៧ សប្ដាហ៍ (៤៩)ថ្ងៃ ឥតមានសោយអាហារដទៃទៀត ។ ក្នុងរយៈកាល ៤៩ ថ្ងៃនោះ ព្រះអង្គមិនសោយអាហារ, មិនស្រង់ទឹក, មិនលុបលាងព្រះឱស្ឋ, មិនបន្ទោបង់វច្ចៈក្នុងសរីរៈ, ទ្រង់ញុំាងកាលឱ្យកន្លងទៅដោយសុខក្នុងឈាន និងមគ្គផល តែមួយយ៉ាងប៉ុណ្ណោះ ។

ព្រះបរមពោធិសត្វ លុះសោយមធុបាយាសនោះរួចហើយ ទ្រង់កាន់ភាជន៍មាសទៅដាក់បណ្ដែតក្នុងស្ទឹង អធិដ្ឋានថា បើអាត្មាអញនឹងបានត្រាស់

ជាព្រះពុទ្ធក្នុងថ្ងៃនេះពិតមែន សូមឱ្យភាជន៍មាសនេះអណ្តែតច្រាសខ្សែទឹកឡើងទៅ. បើមិនអាចទេ សូមឱ្យអណ្តែតតាមខ្សែទឹកទៅចុះ ។ ភាជន៍នោះឯង ហាក់ដូចជាមានចេតនា ក៏អណ្តែតកាត់ទទឹងខ្សែទឹកដល់ទៅពាក់កណ្តាលស្ទឹង ហើយក៏អណ្តែតច្រាសខ្សែទឹកលឿនទៅខាងលើ អស់ប្រមាណជា ៨០ ហត្ថ ហើយក៏លិចចុះទៅក្នុងអន្លង់មួយ ជិតទីជាលំនៅនៃកាឡនាគរាជ. ទៅប៉ះទង្គិចនឹងភាជន៍របស់ព្រះពុទ្ធ ៣ ព្រះអង្គអំពីបូរាណ លាន់ឮសូរកឹរៗ (ក្រឹកៗ) ហើយឋិតនៅពីក្រោមភាជន៍បូរាណទាំង ៣ នោះឯង ។ ខណៈនោះ កាឡនាគរាជបានឮសូរភាជន៍ទង្គិចគ្នា ក៏គិតថាពីថ្ងៃម្សិលមិញ ព្រះពុទ្ធបានត្រាស់មួយព្រះអង្គ. ឥឡូវថ្ងៃនេះ ព្រះពុទ្ធបានត្រាស់មួយព្រះអង្គទៀតហើយ ។ ទើបចូលទៅជិតភាជន៍នោះពោលសរសើរព្រះពុទ្ធគុណ ដោយច្រើនបទជាអនេក ។

ចំណែកខាងព្រះពោធិសត្វ ទ្រង់សំរាកព្រះកាយក្នុងសាលវ័ន (ព្រៃសាលព្រឹក្ស) ទៀបស្ទឹង. លុះសាយណ្ហសម័យ ទ្រង់ស្តេចយាងចេញចាកសាលវ័នឆ្ពោះទៅកាន់ពោធិព្រឹក្ស ។ រុក្ខាលតាជាតិទាំងសងខាងមាគ៌ាក៏បញ្ចេញផ្កាបូជា. ទាំងពួកទេវតាក្នុងលោកធាតុទាំង ១ ម៉ឺន ក៏ថ្វាយសព្ទសាធុការបូជាព្រះពោធិសត្វ ដោយគ្រឿងក្រអូបនិងផ្កាគ្រប់ៗគ្នា ។ សម័យនោះ សោត្ថិយព្រាហ្មណ៍កំពុងរែកស្មៅ (ស្មៅកុសៈ,ស្មៅស្បា) ដើរមកតាមផ្លូវបានជួបនឹងព្រះពោធិសត្វ. ដឹងអាការៈនេះហើយ ក៏យកស្មៅ ៨ ក្តាប់ថ្វាយព្រះអង្គ។ ព្រះពោធិសត្វទទួលស្មៅនោះហើយ ទ្រង់ស្តេចទៅដល់ពោធិព្រឹក្សប្រទក្សិណ ហើយគង់ត្រង់ទក្ខិណទិសនៃពោធិព្រឹក្ស បែរព្រះភ័ក្ត្រទៅខាងឧត្តរទិស. ចក្រវាឡត្រង់ទក្ខិណទិសនោះៗ ក៏កំរើកញាប់ញ័រហាក់ដូចជាក្រាប

ទូលថា ទីនេះមិនមែនជាកន្លែងកើតរតនបល្ល័ង្កទេ. ទ្រង់ទៅគង់ខាងបច្ឆិមទិសក្តី, ខាងឧត្តរទិសក្តី ចក្រវាឡក្នុងទីនោះៗ ក៏កំរើកញាប់ញ័រហាក់ដូចជាក្រាបទូលថា ទីនេះមិនមែនជាកន្លែងកើតរតនបល្ល័ង្កដូចគ្នាដែរ ។ ព្រះអង្គទ្រង់ជ្រាបហេតុនោះហើយ ទើបស្តេចយាងទៅគង់បុរត្ថិមទិស បែរព្រះភ័ក្ត្រទៅបច្ឆិមទិស (ទិសខាងលិច) ទីនោះក៏ស្ងប់ស្ងៀមឥតកំរើកញាប់ញ័រឡើយ. ព្រះអង្គសន្និដ្ឋានថា ទីនេះឯងជាទីកើតរតនបល្ល័ង្ក ទើបទ្រង់ក្រាលស្មៅទាំង ៨ ក្តាប់ត្រង់ទីនោះតាមធម្មតា. បល្ល័ង្កកំពស់ ១៤ ហត្ថ ក៏កើតឡើងប្រាកដក្នុងខណៈនោះភ្លាម. ឯស្មៅទាំង ៨ ក្តាប់ ក៏តាំងនៅជាកម្រាលតាមសភាពខ្លួនដដែល. មិនមែនកើតទៅជាបល្ល័ង្កដោយសារស្មៅនោះទេ ។ លុះរតនបល្ល័ង្កផុសឡើងប្រាកដហើយ ព្រះមហាសត្តទ្រង់ពែនព្រះភ្នែនបែរព្រះបិដ្ឋិទៅខាងពោធិព្រឹក្ស បែរព្រះភ័ក្ត្រមកខាងបុរត្ថិមទិស **(ទិសខាងកើត)** ទ្រង់តាំងព្រះហឫទ័យប្រកបដោយព្យាយាមដ៏មាំថា "ស្បែកក្តី សរសៃក្តី ឆ្អឹងក្តី របស់អាត្មាអញ ចូរឱ្យនៅសល់ចុះ ត្រង់សាច់និងឈាមទាំងអស់ក្នុងសរីរៈនេះ ចូរឱ្យរីងស្ងួតចុះ, បើមិនបានដល់នូវសម្មាសម្ពោធិញ្ញាណក្នុងទីនេះទេ អាត្មាអញ នឹងមិនទម្លាយនូវភ្នែននេះឡើយ ។

ក្នុងកាលនោះ សក្កទេវរាជយកសង្ខមកផ្លុំថ្វាយ. គន្ធព្វទេវបុត្រយកពិណមកដេញប្រគំថ្វាយ. សុយាមទេវបុត្រយកចាមរទិព្វមកបក់ថ្វាយ. សហម្បតីព្រហ្មយកស្វេតច្ឆ័ត្រមកបាំងថ្វាយ. មហាកាឡនាគនាំពួកនាគកញ្ញាមករាំថ្វាយ. ពួកទេវតាក្នុងចក្រវាឡទាំងមួយម៉ឺន នាំយកផ្កាកម្រងនិងគ្រឿងក្រអូបជាទិព្វមកធ្វើសក្ការបូជា ព្រមទាំងថ្វាយស័ព្ទសាធុការចំពោះព្រះពោធិសត្វគ្រប់ៗគ្នា ហើយឋិតនៅក្នុងទីនោះឯង ។ ចប់ សុជាតាកថា

## ១១. មារវិជយកថា

សម័យនោះ ទេវបុត្តមារមានគំនិតអាក្រក់គិតថា សិទ្ធត្ថកុមារនេះប្រាថ្នានឹងកន្លងនូវវិស័យរបស់អញ. ឥឡូវអញមិនឱ្យសិទ្ធត្ថកុមារនេះ កន្លងអំណាចអញបានឡើយ ។ លុះគិតហើយ ទើបចេញទៅកាន់សម្នាក់នៃពលមារ ឃោសនាកេណ្ឌពលមារចេញមក ។ ឯសេនាមារនោះ ពីខាងមុខនៃទេវបុត្តមារកម្រាស់ ១២ យោជន៍. ពីខាងឆ្វេងនិងខាងស្តាំក៏មានកម្រាស់ ១២ យោជន៍ដូចគ្នា ។ ចំណែកខាងសេនាមារដែលឋិតនៅពីខាងក្រោយច្រើនតាន់តាប់ ដេរដាសពាសពេញដរាបដល់កណ្តាប់ចក្រវាឡ. នៅពីខាងលើមានកម្រាស់ ៩ យោជន៍. ឯសម្លេងដែលមារឃោសនាឡើងនោះ ក៏លាន់ឮកងរំពងខ្ទរខ្ទារ ចេញទៅចម្ងាយមួយសែនយោជន៍ជុំវិញ ហាក់ដូចជាសូរសន្ធឹកញ័រកក្រើកផែនដីទាំងមូល ។ គ្រានោះ ទេវបុត្តមារជិះដំរីគិរីមេខលៈជាពាហនៈ មានកំពស់ ១៥០ យោជន៍ និម្មិតដៃមួយពាន់កាន់អាវុធផ្សេងៗ ។ ចំណែកខាងសេនាមារឯទៀត ក៏និម្មិតកាយផ្សេងៗគ្នា មានសម្បុរខៀវនិងលឿងជាដើម មានដៃកាន់អាវុធ ក៏ផ្សេងៗគ្នាដែរ. នាំគ្នាមកចោមរោមព្រះពោធិសត្វ ។

កាលពលមារលើកចូលមកជិតដល់ពោធិមណ្ឌដ្ឋាន ទេវតាទាំងឡាយនៅក្នុងចក្រវាឡមួយម៉ឺន ដែលមកចោមរោមព្រះពោធិសត្វនោះ គ្រាន់តែឮសូរសន្ធឹកគឹកកងនៃសេនាមារលើកចូលមក ក៏នាំគ្នារត់ខ្ចាត់ខ្ចាយទៅកាន់ទីដទៃផ្សេងៗអស់ទៅ ។ ស្តេចកាឡនាគ ក៏ទាំនាគកញ្ញាទាំងអស់មុជជ្រែកផែនដី ចូលទៅកាន់ពិភពនាគមានមន្ទីរប្រមាណ ៥០០យោជន៍ ហើយដេកយកដៃខ្ទប់មុខ ។ មហាព្រហ្ម ក៏ចាប់កំពូលស្វេតច្ឆត្រហោះរត់ទៅកាន់ព្រហ្ម-

លោកវិញ ។ ក្នុងខណៈនោះ សូម្បីតែទេវតាមួយរូប ក៏មិនអាចឋិតនៅក្នុងទីនោះបានឡើយ ។

កាលបើពួកទេវតារត់ទៅអស់ហើយ ព្រះមហាបុរសគង់នៅតែមួយព្រះអង្គឯង ហាក់ដូចជាមហាព្រហ្មឋិតនៅក្នុងវិមាន ឥតខ្លាចពលមារទាំងនោះឡើយ ។

គ្រានោះ មារាធិរាជប្រកាសប្រាប់បរិស័ទរបស់ខ្លួនថា នែអ្នកទាំងឡាយ ! ធម្មតាបុរសដទៃ ឱ្យស្មើនឹងព្រះសិទ្ធត្ថៈជាបុត្រនៃព្រះបាទសុទ្ធោទនៈនេះគ្មានទេ. យើងមិនអាចនឹងធ្វើសង្គ្រាមចូលគយុទ្ធ ក្នុងទីចំពោះពីខាងមុខនៃព្រះសិទ្ធត្ថៈនេះបានឡើយ. យើងចូលទៅបានតែពីខាងឆ្វេង ខាងស្តាំនិងខាងក្រោយប៉ុណ្ណោះ ។ ឯមហាបុរស ទ្រង់ទតទៅឃើញទិសទាំងបីខាង សូន្យស្ងាត់ឥតមានទេវតាមួយរូបឡើយ ព្រោះទេវតាទាំងនោះរត់ទៅអស់ហើយ. ទ្រង់ឃើញសុទ្ធតែពលមារលើកមកខ្លាន់ខ្លាប់ អំពីខាងទិសឧត្តរ ទើបទ្រង់ព្រះតម្រិះថា ជនទាំងអម្បាលនេះ ធ្វើសេចក្តីព្យាយាមដ៏ធំព្រោះអាស្រ័យតែអាត្មាអញតែម្នាក់ឯង. ក្នុងទីនេះ មាតាបិតាក្តី បងប្អូនក្តី ញាតិណាមួយក្តី របស់អាត្មាអញ មិនមានសោះឡើយ មានតែបារមីទាំង ១០ ទុកដូចជាញាតិជាបរិវារនៃអាត្មាអញ អស់កាលជាយូរណាស់មកហើយ ។ ព្រះអង្គទ្រង់នឹករំពឹងនូវបារមីទាំង ១០ ស្រេចហើយ ក៏គង់ស្ងៀមព្រងើយ ។

លំដាប់នោះ ទេវបុត្តមារបណ្តាលនូវមណ្ឌលនៃខ្យល់ ឱ្យតាំងឡើងដោយបំណងថា នឹងឱ្យព្រះសិទ្ធត្ថៈរត់ចេញដោយខ្យល់នេះ ។ ឯខ្យល់នោះក៏បណ្តាលមកអំពីទិសទាំង ៤ មានកម្លាំងខ្លាំងអាចបក់បោកបំបាក់កំពូលភ្នំសូម្បីមានទំហំប្រមាណកន្លះយោជន៍ ពីរយោជន៍ ឬបីយោជន៍ក៏បាន. លុះបក់

មកដល់ព្រះពោធិសត្វ សូម្បីត្រឹមតែជាយចីវរ ក៏ពុំអាចនឹងបក់ឱ្យកំរើកបានឡើយ ។ បន្ទាប់ពីនោះ ទេវបុត្តមារក៏បណ្ដាលភ្លៀងធំឱ្យធ្លាក់ចុះមក ដោយបំណងនឹងឱ្យជោរជន់លិចសម្លាប់ព្រះពោធិសត្វ ។ ឯភ្លៀងនោះឯង មានកម្រាស់មួយរយស្រទាប់ មួយពាន់ស្រទាប់ជាដើម ធ្លាក់ចុះមកពីខាងលើហូរច្រោះ រូងខូងផែនដី ដោយកម្លាំងធារទឹកភ្លៀង ប៉ុន្តែដោយបុញ្ញតេជានុភាពរបស់ព្រះពោធិសត្វ ទឹកភ្លៀងនោះសូម្បីតែមួយតំណក់ ក៏មិនអាចធ្វើឱ្យទទឹកចីវររបស់ព្រះអង្គបានឡើយ ។ បន្ទាប់ពីនោះទៀត ទេវបុត្តមារក៏បណ្ដាលឱ្យកើតមានភ្លៀងដុំថ្ម, ភ្លៀងគ្រឿងប្រហារមានដាវនិងលំពែងជាដើម, ភ្លៀងរងើកភ្លើង, ភ្លៀងផេះក្ដៅ, ភ្លៀងដីខ្សាច់, ភ្លៀងភក់, ភ្លៀងទាំងអស់នេះ ក៏មិនអាចមកប៉ះពាល់ព្រះពោធិសត្វបានឡើយ, ត្រឡប់ធ្លាក់ក្លាយទៅជាផ្កាទិព្វ បូជាទៀបបាទមូលនៃព្រះពោធិសត្វវិញ ។ បន្ទាប់ពីនោះមកទៀត ទេវបុត្តមារ បណ្ដាលឱ្យងងឹតផ្សែងអព្ទគ្រប់ទិសទាំង ៤ ដោយបំណងនឹងបន្លាចឱ្យព្រះពោធិសត្វរត់ចេញ ។ ឯងងឹតនោះ ក៏អន្តរធានបាត់អស់ទៅ មិនអាចមកប៉ះពាល់ដល់ព្រះពោធិសត្វបានឡើយ ប្រៀបដូចជារស្មីនៃព្រះអាទិត្យ ដែលរះឡើងកម្ចាត់នូវងងឹត ឱ្យអន្តរធានទៅដូច្នោះឯង ។

ទេវបុត្តមារ មិនអាចនឹងញុំាងព្រះពោធិសត្វ ឱ្យរត់ទៅដោយហេតុទាំង ៩ ប្រការ មានខ្យល់និងភ្លៀងជាដើមបាន, ទើបបង្គាប់ទៅពួកពលសេនាថា "នែវើយ ! អ្នករាល់គ្នា ចូរទៅចាប់ព្រះសិទ្ធត្ថៈនេះសម្លាប់ចោលទៅ ឬ បណ្ដេញឱ្យចេញពីនោះទៅ !" ចំណែកខាងមារាធិរាជ ដែលជិះលើដំរីគិរីមេខលៈ ដៃកាន់ចក្រាវុធ បរដំរីសម្រុកចូលទៅជិតព្រះពោធិសត្វហើយពោលថា នែសិទ្ធត្ថៈ ! ចូរអ្នកក្រោកចេញចាកបល្ល័ង្កនេះ ៗ មិនត្រូវ

បានអ្នកទេ, ត្រូវបានយើងទេតើ ! ។ ព្រះមហាបុរស ទ្រង់ព្រះសណ្ដាប់ពាក្យមារដូច្នោះ ក៏ត្រាស់តបវិញថា នែមារ ! បារមីទាំង ១០ ប្រការ មានទានបារមីជាដើមក្ដី មហាបរិច្ចាគទាំង ៥ ប្រការ មានអង្គបរិច្ចាគជាដើមក្ដី ចរិយាទាំង ៣ ប្រការ មានញាតត្ថចរិយាជាដើមក្ដី មិនមែនអ្នកឯងបានបំពេញមកទេ, បល្ល័ង្កនេះ មិនមែនកើតឡើងសំរាប់អ្នកឯងទេ, បល្ល័ង្កនេះ កើតឡើងដោយសារបុណ្យបារមីរបស់យើងទេតើ ! ។ មារាធិរាជបានឮហើយ ក៏រឹងរឹតតែក្រេវក្រោធខ្លាំងឡើង ចាប់យកចក្រាវុធចោលតម្រង់ទៅព្រះមហាបុរស, ឯចក្រាវុធនោះ ក៏ក្លាយទៅជាពិតានឋិតនៅខាងលើនៃព្រះមហាបុរស, ដែលទ្រង់កំពុងនឹករំពឹងនូវបារមីទាំង ១០ ប្រការ ។ ចំណែកខាងមារបរិស័ទឯទៀត ក៏លើកយកកំពូលភ្នំធំៗ ចោលតម្រង់សំដៅទៅព្រះមហាបុរស, ឯកំពូលភ្នំធំៗនោះ ក៏ក្លាយជាផ្កាកម្រងធ្លាក់មកបូជាទៅវិញ ។ ពួកទេវតាដែលរត់ចោលព្រះពោធិសត្វ ទៅឋិតនៅឯកណ្ដាប់មាត់ចក្រវាឡ គ្រាន់តែបញ្ចេញ ក អើតសីសៈមើលមកព្រះពោធិសត្វ ក៏គិតគ្នាថា អត្តភាពរបស់ព្រះសិទ្ធត្ថៈ ដែលមានរូបឆោមលោមពណ៌ល្អនោះ ប្រហែលជាវិនាសដោយដៃមារទៅហើយទេដឹង ? ។

លំដាប់នោះ ព្រះមហាបុរសទ្រង់ត្រាស់ទៅមារថា ធម្មតាព្រះពោធិសត្វ ដែលមានបារមីបានបំពេញមកហើយ រមែងមានបល្ល័ង្កកើតឡើងសំរាប់យើងជាពោធិសត្វក្នុងថ្ងៃជាទីត្រាស់ដឹង ។ ទើបទ្រង់សួរទៅមារថា នែមារ ! បើអ្នកថាបល្ល័ង្កនេះត្រូវបានអ្នក, តើអ្នកណាជាសាក្សីរបស់អ្នក ? មារក៏លើកដៃទៅពួកមារទាំងអស់ ហើយពោលថា ពលសេនាទាំងឡាយនេះជាសាក្សីរបស់យើង ។ ខណៈនោះ សម្លេងក៏លាន់ឮគឹកកងរំពងព្រមគ្នាឡើង

ស្ទើរស្រុតផែនដី ដោយមារបរិស័ទស្រែកថា យើងជាសាក្សី ! យើងជាសាក្សី ! ។ មារត្រឡប់សួរទៅមហាបុរសវិញថា នែសិទ្ធត្ថៈ ! អ្នកណាជាសាក្សីរបស់អ្នក ? ព្រះមហាបុរសត្រាស់តបវិញថា នែមារ ! សាក្សីរបស់អ្នកសុទ្ធសឹងតែមានចេតនាទាំងអស់. ឯក្នុងទីនេះ បុគ្គលណាមួយប្រកបដោយចេតនា ឈ្មោះថា ជាសាក្សីរបស់យើងមិនមានសោះឡើយ មានតែមហាទានដែលយើងបានបរិច្ចាគ ក្នុងកាលដែលកើតជាស្តេចវេស្សន្តរនោះឯង ជាសាក្សីរបស់យើង. ទើបព្រះអង្គបញ្ចេញព្រះហស្តស្តាំពីក្នុងចីវរ[១] ចង្អុលទៅផែនដីថា នែមហាប្រឹថពី ! អ្នកឯងជាសាក្សី ឬមិនមែនជាសាក្សីទេ ក្នុងកាលដែលយើងបានបរិច្ចាគមហាទាន ក្នុងជាតិជាស្តេចវេស្សន្តរនោះ ? មហាប្រឹថពី ក៏បន្លឺសម្លេងខ្ទរខ្ទារឡើង ហាក់ដូចជាក្រាបទូលថា ខ្ញុំហ្នឹងឯង ជាសាក្សីរបស់ព្រះអង្គ ។ កាលដែលព្រះពោធិសត្វកំពុងពិចារណានូវមហាទានដែលព្រះអង្គបានឱ្យដល់ពួកស្មូម ក្នុងអត្តភាពជាព្រះវេស្សន្តរនោះ ដំរីគិរីមេខលៈមានកំពស់ប្រមាណ ១៥០ យោជន៍ ពុំអាចទប់ទល់អាត្មាបាន ក៏ទន់ជង្គង់លុតចុះលើផែនដី. ឯមារសោត ក៏លើកដៃទាំងមួយពាន់ដាក់លើត្បូងពោលសរសើរព្រះពោធិសត្វថា :

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**
**សទេវកស្មឹ លោកស្មឹ នត្ថិ តេ បដិបុគ្គលោ**
**តុវំ ពុទ្ធោ តុវំ សត្ថា តុវំ មារាភិភូ មុនី**
**តុវំ អនុសយេ ឆិន្ទោ តិណ្ណោ តារេសិ មំ បជំ**[២] ។

---

១-តាមសេចក្តីនេះឃើញថា ក្នុងវេលានោះ ព្រះមហាសត្វទ្រង់ឃ្លុំចីវរ ។ ២-បាលីគាថានេះគួរសូត្រក្នុងពិធីពុទ្ធាភិសេក ។

បពិត្របុរសជាអាជានេយ្យ ! ខ្ញុំព្រះអង្គ សូមនមស្សការចំពោះព្រះអង្គ បពិត្រព្រះអង្គដ៏ខ្ពង់ខ្ពស់ ! ខ្ញុំព្រះអង្គ សូមនមស្សការចំពោះព្រះអង្គ, ក្នុងលោកនេះព្រមទាំងទេវលោក មិនមានបុគ្គលណាមួយប្រៀបផ្ទឹមនឹងព្រះអង្គបានឡើយ, ព្រះអង្គជាព្រះពុទ្ធ, ព្រះអង្គជាសាស្តាចារ្យ, ព្រះអង្គជាអ្នកប្រាជ្ញទ្រង់គ្របសង្កត់នូវពួកមារ, ព្រះអង្គជាអ្នកកាត់ផ្តាច់នូវអនុសយកិលេស ទ្រង់ឆ្លងផុតចាកសង្សារហើយ, សូមទ្រង់ចម្លងនូវសត្វជាខ្ញុំព្រះអង្គផង ។

លុះមារពោលនមស្សការយ៉ាងនេះរួចហើយ ក៏ហោះរត់ទៅកាន់ឋានជាលំនៅរបស់ខ្លួនវិញ ។ ចំណែកខាងពលមារទាំងឡាយ ក៏នាំគ្នារត់បែកខ្ញែកទៅកាន់ទិសតូចទិសធំរៀងៗខ្លួនវិញដែរ (ឥតមានពលមារណាមួយអន្តរាយឡើយ) ។ លំដាប់នោះ ទេវតាទាំងឡាយបានឃើញពលមារដល់នូវបរាជ័យរត់ខ្ចាត់ខ្ចាយទៅអស់ដូច្នោះ ក៏ប្រឹក្សាគ្នាថា មារបរាជ័យចាញ់រត់ទៅអស់ហើយ, ព្រះសិទ្ធត្ថៈមានជ័យជំនះហើយ យើងទាំងឡាយនឹងធ្វើជយបូជាចំ-ពោះព្រះពោធិសត្វ ។ ចំណែកខាងពួកនាគ ក៏ប្រកាសប្រាប់ដល់ពួកនាគ, ពួកគ្រុឌ ក៏ប្រកាសប្រាប់ដល់ពួកគ្រុឌ, ពួកទេវតា ក៏ប្រកាសប្រាប់ដល់ពួកទេវតា, ពួកព្រហ្ម ក៏ប្រកាសប្រាប់ដល់ពួកព្រហ្ម តៗគ្នា, ពួកជនទាំងនោះសុទ្ធតែមានដៃកាន់គ្រឿងក្រអូប និងផ្កាកម្រងជាដើម នាំគ្នាចូលទៅកាន់ពោធិបល្ល័ង្ក មានចិត្តត្រេកអរ ស្រែកឃោសនាថ្វាយជ័យចំពោះព្រះពោធិសត្វគ្រប់ៗគ្នា ក្នុងគ្រានោះថា :

**១. "ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ**
**មារស្ស ច បាបិមតោ បរាជយោ"**
**ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា**

ជយំ តទា នាគគណា មហេសិនោ ។

២."ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ"
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
សុបណ្ណសង្ឃាបិ ជយំ មហេសិនោ ។

៣."ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ"
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា ទេវគណា មហេសិនោ ។

៤."ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ"
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា ព្រហ្មគណាបិ តាទិនោតិ ។

ប្រែថា គ្រានោះ ពួកនាគមានចិត្តរីករាយ ចូលមកជិតពោធិមណ្ឌដ្ឋាន ស្រែកថ្វាយជ័យចំពោះព្រះមហាសត្តជាមហាឫសីថា "ជយោ ព្រះពុទ្ធមានសិរី ! បរាជយោ មារមានចិត្តបាប !" ។

គ្រានោះ ពួកគ្រុឌមានចិត្តរីករាយ ចូលមកជិតពោធិមណ្ឌដ្ឋាន ស្រែកថ្វាយជ័យចំពោះព្រះមហាសត្តជាមហាឫសីថា "ជយោ ព្រះពុទ្ធមានសិរី ! បរាជយោ មារមានចិត្តបាប !" ។

គ្រានោះ ពួកទេវតាមានចិត្តរីករាយ ចូលមកជិតពោធិមណ្ឌដ្ឋាន ស្រែកថ្វាយជ័យចំពោះព្រះមហាសត្តជាមហាឫសីថា "ជយោ ព្រះពុទ្ធមាន

សិរី ! បរាជយោ មារមានចិត្តបាប !" ។

គ្រានោះ ពួកព្រហ្មមានចិត្តរីករាយ ចូលមកជិតពោធិមណ្ឌដ្ឋាន ស្រែកថ្វាយជ័យចំពោះព្រះមហាសត្តជាតាទិបុគ្គល[១] ថា "ជយោ ព្រះពុទ្ធមាន សិរី ! បរាជយោ មារមានចិត្តបាប !" ។

ទេវតាទាំងឡាយក្នុងចក្រវាឡទាំងមួយម៉ឺន បានបូជាគ្រឿងសក្ការៈជាទិព្វហើយ ពោលសរសើរព្រះមហាសត្ត ដោយថ្ងូតិកថាមានប្រការផ្សេងៗ ចំពោះព្រះមហាសត្ត ហើយឋិតនៅក្នុងទីនោះ ។

ចប់ មារាវិជយកថា

## ១២.អភិសម្ពោធិកថា

កាលព្រះអាទិត្យពុំទាន់អស្តង្គតនៅឡើយ, ព្រះមហាបុរសទ្រង់កំចាត់នូវមារព្រមទាំងរេហ៍ពលស្រេចហើយ, ត្រួយស្លឹកពោធិព្រឹក្សមានពណ៌ប្រាកដដូចជាកែវប្រពាឡ ក៏ជ្រុះធ្លាក់មកលើចីវរបូជាព្រះអង្គ ។ លុះដល់ពេលបឋមយាម ព្រះហឫទ័យរបស់ព្រះមហាបុរស តាំងនៅនឹងល្អបរិសុទ្ធផុតចាកនីវរណធម៌, ផូរផង់មិនមានទីទូលពោលគឺកិលេស ប្រាសចាកឧបក្កិលេស, មានសភាពជាចិត្តទន់គួរដល់ភាវនា, មិនញាប់ញ័រទៅតាមអារម្មណ៍ ដោយអំណាចឈានទាំង ៤ ដោយប្រការដូច្នោះហើយ, ព្រះមហាបុរសក៏បង្អោនព្រះហឫទ័យ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ គឺប្រាជ្ញាតាមរលឹកឃើញនូវលំដាប់ខន្ធរបស់ព្រះអង្គ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន គឺរលឹកអតីតជាតិដែលកន្លងទៅហើយ តាំងអំពី ១ ជាតិ, ២ ជាតិ, ៣ ជាតិ, ៤ ជាតិ, ៥ ជាតិ, ១០

---

១-បុគ្គលមិនរំភើប មិនញាប់ញ័រដោយលោកធម៌ជាដើម ហៅថា តាទិបុគ្គល ។

ជាតិ, ២០ ជាតិ, ៣០ ជាតិ, ៤០ ជាតិ, ៥០ ជាតិ, មួយរយជាតិ, មួយពាន់ជាតិ មួយសែនជាតិ, រហូតដល់សំវដ្តកប្ប[១] វិវដ្តកប្ប[២] និងសំវដ្តវិវដ្តកប្ប[៣] ព្រះមហាបុរសទ្រង់ជ្រាបថា អាត្មាអញបានកើតក្នុងទីឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្តត្រកូលយ៉ាងនេះ មានរូបរាងទ្រង់ទ្រាយ និងសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ សោយសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះៗ, លុះច្យុតចាកទីនោះហើយ ក៏ទៅកើតក្នុងទីឯណោះទៀត, លុះបានទៅកើតក្នុងទីឯនោះទៀតហើយ ក៏មានឈ្មោះយ៉ាងនេះ មានគោត្តត្រកូលយ៉ាងនេះ មានរូបរាង និងសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ សោយសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះៗ, លុះច្យុតចាកទីនោះ ទើបបានមកកើតក្នុងទីនេះ ។

ខណៈនោះ អវិជ្ជា គឺសេចក្តីងងឹតល្ងង់ពុំដឹងពុំយល់នូវបុព្វេនិវាសបាត់ទៅហើយ វិជ្ជា គឺសេចក្តីដឹងនូវបុព្វេនិវាសក៏កើតឡើង, សេចក្តីងងឹតបាត់ទៅហើយ ពន្លឺក៏កើតឡើងប្រាកដដល់ព្រះមហាបុរស ក្នុងបឋមយាមនោះ ដូចគ្នានឹងបុគ្គលដែលមិនប្រមាទ មានព្យាយាមញុំាងកិលេសឱ្យក្តៅ មានចិត្តស្ទុងទៅកាន់ព្រះនិព្វាន តែងមានអវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើងដូច្នោះឯង ។

លុះដល់ពេលមជ្ឈិមយាម ព្រះមហាបុរស ក៏បង្អោនព្រះហឫទ័យទៅ

១-កប្បដែលវិនាស គឺភ្លើងដែលកំពុងឆេះ ហៅថា សំវដ្តកប្ប ។ ២-កប្បដែលចំរើន គឺកំពុងកើតឡើងថ្មីទៀត ហៅថា វិវដ្តកប្ប ។ ៣-គិតតាំងពីថ្ងៃដែលកប្បវិនាស ទៅទល់គ្នានឹងភ្លើងឆេះអស់រលីង ហៅថា សំវដ្តកប្ប ១, តាំងពីថ្ងៃឆេះអស់ទៅ នៅសល់តែអាកាសសូន្យធេងទទេ ហៅថា សំវដ្តដ្ឋាយិកប្ប ១, តាំងពីកប្បកកើតឡើងថ្មី ទៅទល់នឹងកាលដែលកើតមានព្រះអាទិត្យព្រះចន្ទ ហៅថា វិវដ្តកប្ប ១, តាំងពីព្រះអាទិត្យព្រះចន្ទកើតឡើង ទៅទល់នឹងកប្បវិនាសទៅវិញ ហៅថា វិវដ្តដ្ឋាយិកប្ប ១, រួមកប្បទាំង ៤ នេះចូលជាមួយគ្នា ហៅថា សំវដ្តវិវដ្តកប្ប ឬហៅថា មហាកប្បក៏បាន ។

ដើម្បីចុតូបបាតញ្ញាណេ គឺប្រាជ្ញាដឹងនូវចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ គឺព្រះអង្គមានទិព្វចក្ខុ កន្លងហួសចក្ខុរបស់មនុស្សធម្មតា, ទ្រង់បានឃើញនូវពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានរូបល្អខ្លះ អាក្រក់ខ្លះ មានគតិល្អខ្លះ គតិអាក្រក់ខ្លះ ។ មួយទៀត ព្រះមហាបុរសទ្រង់ជ្រាបច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ ! សត្វទាំងនេះ ប្រកបដោយកាយទុច្ចរិតខ្លះ ដោយវចីទុច្ចរិតខ្លះ ដោយមនោទុច្ចរិតខ្លះ សត្វទាំងនោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខអំពីសេចក្ដីស្លាប់ រមែងទៅកាន់កំណើតសត្វតិរច្ឆាន ប្រេត អសុរកាយ និងនរក ។ មួយវិញទៀត ព្រះមហាបុរសទ្រង់ជ្រាបច្បាស់ថា អើហ្ន៎ ! សត្វពួកនេះ ប្រកបដោយកាយសុចរិតខ្លះ ដោយវចីសុចរិតខ្លះ ដោយមនោសុចរិតខ្លះ, សត្វទាំងនោះ លុះមានរាងកាយបែកធ្លាយទៅ រមែងទៅកាន់សុគតិ គឺស្ថានសួគ៌ទេវលោក ។ ខណៈនោះ ចក្ខុទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ក៏កើតឡើង ទាំងអវិជ្ជាក៏បាត់ទៅ វិជ្ជាក៏កើតឡើង, សេចក្ដីងងឹតក៏បាត់ទៅ ពន្លឺក៏កើតឡើងប្រាកដដល់ព្រះមហាបុរស ក្នុងមជ្ឈិមយាមនោះ ដូចគ្នានឹងបុគ្គលដែលមិនប្រមាទ មានព្យាយាមញុំាងកិលេសឱ្យក្ដៅ មានចិត្តស្ទួងទៅកាន់ព្រះនិព្វាន តែងមានអវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ដូច្នោះឯង ។

លំដាប់អំពីមជ្ឈិមយាមនោះមក ព្រះមហាបុរសទ្រង់រំពឹងនូវបដិច្ចសមុប្បាទធម៌ ជាអនុលោមបដិលោម គឺទ្រង់ពិចារណាបណ្ដោយចុះនិងច្រាសឡើង អស់បច្ឆិមយាមនៃរាត្រី, ប៉ុន្តែ មុនដំបូងទ្រង់មានសេចក្ដីត្រិះរិះក្នុងព្រះហឫទ័យយ៉ាងនេះថា អើហ្ន៎ ! សត្វលោកនេះ ដល់នូវសេចក្ដីលំបាកណាស់តើ ! រមែងកើតឡើងហើយ ចាស់ ឈឺ ស្លាប់, ស្លាប់កើតៗឥតឈប់

ឥតស្រាក មកតែពីមិនដឹងច្បាស់នូវធម៌ជាគ្រឿងរលាស់ខ្លួនចេញចាកទុក្ខនេះឯង បើមិនដឹងច្បាស់នូវធម៌ជាគ្រឿងរលាស់ខ្លួនចេញចាកទុក្ខ និងជរា និងមរណៈនេះទេ កាលណាឡើយនឹងផុតចាកទុក្ខ គឺជរា និងមរណៈនេះបាន !។

គ្រានោះ ព្រះមហាបុរសទ្រង់រំពឹងជាបដិលោមដូច្នេះថា ធម្មជាតិអ្វីហ្ន៎ ! មានឡើង ទើបមានជរា និងមរណៈ ជរានិងមរណៈកើតមានព្រោះមានអ្វីជាបច្ច័យ ? ព្រះអង្គក៏ទ្រង់ឈ្វេងយល់ដោយប្រាជ្ញាថា កាលបើជាតិមានហើយ ទើបមានជរា និងមរណៈ. ជរា និងមរណៈកើតមាន ព្រោះមានជាតិជាបច្ច័យ ។ លំដាប់នោះ ព្រះមហាបុរស ទ្រង់រំពឹងតទៅទៀតថា ធម្មជាតិអ្វីហ្ន៎ មានឡើង ទើបកើតមានជាតិ ជាតិកើតមាន តើព្រោះមានអ្វីជាបច្ច័យ ? ព្រះអង្គទ្រង់ឈ្វេងយល់ជាលំដាប់តទៅទៀតថា កាលបើភពមានជាតិក៏មាន. ជាតិកើតមាន ព្រោះមានភពជាបច្ច័យ. ភពកើតមាន ព្រោះមានឧបាទានជាបច្ច័យ. ឧបាទានកើតមាន ព្រោះមានតណ្ហាជាបច្ច័យ. តណ្ហាកើតមាន ព្រោះមានវេទនាជាបច្ច័យ. វេទនាកើតមាន ព្រោះមានផស្សៈជាបច្ច័យ. ផស្សៈកើតមាន ព្រោះមានសឡាយតនៈជាបច្ច័យ. សឡាយតនៈកើតមាន ព្រោះមាននាមរូបជាបច្ច័យ. នាមរូបកើតមាន ព្រោះមានវិញ្ញាណជាបច្ច័យ. វិញ្ញាណកើតមាន ព្រោះមានសង្ខារជាបច្ច័យ. សង្ខារកើតមាន ព្រោះមានអវិជ្ជាជាបច្ច័យ ។ ព្រះអង្គពិចារណាស្រាវជ្រាវរកឫសគល់នៃសេចក្តីទុក្ខ ឃើញច្បាស់ដូច្នេះហើយ ទើបទ្រង់រំពឹងជាអនុលោមបណ្តោយចុះទៅវិញថា សង្ខារកើតមាន ព្រោះមានអវិជ្ជាជាបច្ច័យ. វិញ្ញាណកើតមាន ព្រោះមានសង្ខារជាបច្ច័យ. នាមរូបកើតមាន ព្រោះមានវិញ្ញាណជាបច្ច័យ. សឡាយតនៈកើតមាន ព្រោះមាននាមរូបជាបច្ច័យ. ផស្សៈកើតមាន ព្រោះមាន

សឡាយតនៈជាបច្ច័យ, វេទនាកើតមាន ព្រោះមានផស្សៈជាបច្ច័យ, តណ្ហាកើតមាន ព្រោះមានវេទនាជាបច្ច័យ, ឧបាទានកើតមាន ព្រោះមានតណ្ហាជាបច្ច័យ, ភពកើតមាន ព្រោះមានឧបាទានជាបច្ច័យ, ជាតិកើតមាន ព្រោះមានភពជាបច្ច័យ, ជរានិងមរណៈកើតមាន ព្រោះមានជាតិជាបច្ច័យ, សេចក្ដីសោកខ្សឹកខ្សួល សេចក្ដីលំបាកកាយ លំបាកចិត្ត និងសេចក្ដីចង្អៀតណែនតានតឹងចិត្ត ក៏កើតឡើងព្រម, ការកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានដោយអាការយ៉ាងនេះឯង ។ ចក្ខុ ញាណ បញ្ញា វិជ្ជា ពន្លឺ ក្នុងធម៌ទាំងឡាយ ដែលព្រះមហាបុរសមិនធ្លាប់បានឮ មិនធ្លាប់បានស្ដាប់ក្នុងកាលមុន ក៏កើតឡើងដល់ព្រះអង្គក្នុងខណៈនោះ ។ គ្រានោះឯង ព្រះមហាបុរស ទ្រង់រំពឹងរកសេចក្ដីរលត់ជាបដិលោមដូច្នេះថា ធម្មជាតិអ្វីមិនមានហ្ន៎ ទើបជរានិងមរណៈមិនមាន ? ជរានិងមរណៈរលត់ទៅ តើព្រោះរលត់ធម្មជាតិអ្វី ? ព្រះអង្គក៏ទ្រង់ឈ្វេងយល់ដោយប្រាជ្ញាថា ជរានិងមរណៈដែលនឹងរលត់ទៅ ព្រោះរលត់ជាតិ, ជាតិដែលនឹងរលត់ទៅ ព្រោះរលត់ភព, ភពដែលនឹងរលត់ទៅ ព្រោះរលត់ឧបាទាន, ឧបាទានដែលនឹងរលត់ទៅ ព្រោះរលត់តណ្ហា, តណ្ហាដែលនឹងរលត់ទៅ ព្រោះរលត់វេទនា, វេទនាដែលនឹងរលត់ទៅ ព្រោះរលត់ផស្សៈ, ផស្សៈដែលនឹងរលត់ទៅ ព្រោះរលត់សឡាយតនៈ, សឡាយតនៈដែលនឹងរលត់ទៅ ព្រោះរលត់នាមរូប, នាមរូបដែលនឹងរលត់ទៅ ព្រោះរលត់វិញ្ញាណ, វិញ្ញាណដែលនឹង រលត់ទៅ ព្រោះរលត់សង្ខារ, សង្ខារដែលនឹងរលត់ទៅ ព្រោះរលត់អវិជ្ជា ។

លំដាប់នោះ ព្រះមហាបុរស ពិចារណាស្រាវជ្រាវរកឫសគល់នៃសេចក្ដីរលត់ទុក្ខឃើញច្បាស់ដូច្នេះហើយ ទើបទ្រង់ពិចារណាបណ្ដោយចុះទៅ

វិញទៀតថា ការរលត់សង្ខារ ព្រោះរលត់អវិជ្ជា, ការរលត់វិញ្ញាណ ព្រោះរលត់សង្ខារ, ការរលត់នាមរូប ព្រោះរលត់វិញ្ញាណ, ការរលត់សឡាយតនៈ ព្រោះរលត់នាមរូប, ការរលត់ផស្សៈ ព្រោះរលត់សឡាយតនៈ, ការរលត់វេទនា ព្រោះរលត់ផស្សៈ, ការរលត់តណ្ហា ព្រោះរលត់វេទនា, ការរលត់ឧបាទាន ព្រោះរលត់តណ្ហា, ការរលត់ភព ព្រោះរលត់ឧបាទាន, ការរលត់ជាតិ ព្រោះរលត់ភព, ជរានិងមរណៈរលត់ ព្រោះរលត់ជាតិ, កាលបើជាតិរលត់ហើយ សេចក្តីសោក ខ្សឹកខ្សួល សេចក្តីលំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតណែនតានតឹងចិត្ត ក៏រលត់អស់ទៅដែរ, ការរលត់នៃកងទុក្ខទាំងអស់នេះ រមែងមានដោយអាការយ៉ាងនេះឯង ។ ចក្ខុ ញាណ បញ្ញា វិជ្ជា ពន្លឺ ក្នុងធម៌ទាំងឡាយ ដែលព្រះមហាបុរសមិនធ្លាប់បានឮ មិនធ្លាប់បានស្តាប់ក្នុងកាលមុន ក៏កើតឡើងដល់ព្រះអង្គ ក្នុងខណៈនោះ ។ កាលដែលព្រះមហាបុរសកំពុងពិចារណានូវបច្ចយាការ គឺបដិច្ចសមុប្បាទធម៌ ដ៏ប្រកបដោយអង្គ ១២ ប្រការ ជាអនុលោមបដិលោម ដោយអំណាចនៃសេចក្តីវិនាស និងសេចក្តីចំរើនយ៉ាងនេះ លោកធាតុទាំងមួយម៉ឺនក៏រញ្ជួយកម្រើកអស់វារៈ ១២ ដង ដរាបដល់ទឹកទ្រទ្រដីជាទីបំផុត ។

ក្នុងវេលាដែលព្រះមហាបុរស បានដល់នូវភាពជាអង្គព្រះមហាសត្វទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ គឺព្រះអង្គបានជាព្រះសព្វញ្ញុពុទ្ធហើយ, លោកធាតុទាំងមួយម៉ឺនសុទ្ធសឹងប្រដាប់ដោយគ្រឿងលំអ គឺទង់ជ័យដែលទេវតាលើកឡើងក្នុងកណ្តាប់ចក្រវាឡ ខាងបាចីនទិស (ខាងកើត) ដរាបដល់កណ្តាប់ចក្រវាឡខាងបច្ឆិមទិស (ខាងលិច), ពីកណ្តាប់ចក្រវាឡខាងបច្ឆិមទិស ដរាបដល់កណ្តាប់ចក្រវាឡខាងបាចីនទិសវិញ, ពីកណ្តាប់ចក្រវាឡ

ខាងឧត្តរទិស (ខាងជើង) ដរាបដល់កណ្ដាប់ចក្រវាឡខាងទក្ខិណទិស (ខាងត្បូង). ពីកណ្ដាប់ចក្រវាឡខាងទក្ខិណទិស ដរាបដល់កណ្ដាប់ចក្រវាឡខាងឧត្តរទិសវិញ. ទង់ជ័យទាំងនោះ ដែលទេវតាលើកឡើង តាំងពីផ្ទៃផែនដី ដរាបដល់ព្រហ្មលោក. តាំងអំពីព្រហ្មលោក ដរាបទល់នឹងផ្ទៃផែនដីវិញ ។ ដើមឈើ មែកឈើ និងវល្លិ៍ ក៏មានផ្ការីកស្គុះស្គាយសំយុងចុះ, ផ្កាឈូកដែលរីកសំយុងចុះឯអាកាសក៏មាន. ដែលទម្លាយផែនដី ផែនថ្ម ដុះឡើងហើយរីកក៏មាន ។ លោកធាតុទាំងមួយម៉ឺន សុទ្ធសឹងតែដេរដាសពាសពេញដោយទង់ជ័យ និងផ្កាទាំងអស់ ។

គ្រានោះ ព្រះអរហន្តសម្មាសម្ពុទ្ធ ដែលពួកទេវតាបូជាដោយគ្រឿងសក្ការៈ រាប់មិនបានប្រមាណមិនអស់យ៉ាងនេះ ទ្រង់សរសើរនូវជំនះរបស់ព្រះអង្គ ដោយឧទានគាថា ដែលព្រះពុទ្ធគ្រប់ព្រះអង្គពុំដែលលះបង់ តែងបន្លឺ ដូច្នេះថា :

**អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ**
**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
**សព្វា តេ ផា សុកា ភគ្គា គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគាតិ ។**

កាលអាត្មាអញ មិនទាន់បានជួបប្រទះនូវពោធិញ្ញាណនៅឡើយ វិលតែស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព ហើយអន្ទោលទៅអស់សង្សារ មានជាតិដ៏ច្រើន. ជាតិគឺការកើតរឿយៗ រមែងនាំមកនូវសេចក្ដីទុក្ខ. នែជាងផ្ទះគឺតណ្ហា ! (ឥឡូវនេះ) អាត្មាអញបានឃើញអ្នកឯងច្បាស់

ហើយ. អ្នកឯងនឹងធ្វើនូវផ្ទះគឺអត្តភាព ឱ្យអាត្មាអញទៀតពុំបានឡើយ. ឆ្អឹងជំនី គឺកិលេសទាំងអស់របស់អ្នកឯង អាត្មាអញបានបំបាក់ចោលអស់ហើយ. ទាំងកំពូលនៃផ្ទះ គឺអវិជ្ជា របស់អ្នកឯងសោតទៀត អាត្មាអញបានបំបាក់ចោលអស់ហើយដែរ. ចិត្តរបស់អាត្មាអញ បានដល់នូវនិព្វានដែលឥតសង្ខារហើយ. អាត្មាអញបានដល់អរហត្តផល គឺការអស់តណ្ហាទាំងឡាយហើយ ។

កាលដែលព្រះអង្គបានត្រាស់ជាព្រះ **អរហំសម្មាសម្ពុទ្ធ** ហើយ ទ្រង់គង់នៅលើរតនបល្ល័ង្ក ក្រោមពោធិព្រឹក្សនោះអស់ ៧ ថ្ងៃ ។ (ព្រះអង្គបានត្រាស់ ក្នុងថ្ងៃ **ពុធ ពេញបូណ៌មី** ខែ **ពិសាខ** ឆ្នាំ **រកា** ក្នុងព្រះជន្មគម្រប់ **៣៥** ឆ្នាំ. ទ្រង់ព្រះផ្នួសបាន **៦** ព្រះវស្សា) ។

សេចក្តីដំណាល អំពីប្រវត្តិនៃ **ព្រះសព្វញ្ញុពុទ្ធ** ជាបរមគ្រូនៃយើង ចាប់តាំងអំពីព្រះអង្គនៅជាសន្តុសិតទេវបុត្រ ឋិតនៅក្នុងតុសិតបុរី នាឋានទេវលោក ដរាបដល់បានត្រាស់ដឹង គង់លើរតនបល្ល័ង្កក្រោមពោធិព្រឹក្សនេះ ហៅថា **អវិទូរេនិទាន** ដោយប្រការដូច្នេះឯង ។

ចប់ អភិសម្ពោធិកថា

**ចប់ ពុទ្ធប្បវត្តិ អវិទូរេនិទាន ភាគ ២**

**វាយកុំព្យូទ័រចម្លងដោយ ភិក្ខុ ជួន សុចិត្ត អាចិណ្ណកល្យាណោ**
**វត្តកំពូលមាស ឃុំឫស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត**
នៅថ្ងៃ ព្រហស្បតិ៍ ៣ កើត ខែ អស្សុជ ឆ្នាំ រោងចត្វាស័ក ព.ស ២៥៥៦
ត្រូវនឹងថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ សយ សិលា

វិច្ឆិកា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ី ដារា និងលោកស្រី សុន ដាវី ព្រមទាំងលោកស្រី បុប្ផា ដីឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្វារ ដី ឡូប៉ីស និងលោកម្តាយ ឌិន សៅខុន

សូមអរគុណ

ខៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

### បុគ្គលឯក

បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើងដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ តើបុគ្គលឯកនោះ គឺនរណា ?

"គឺព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ"


មានជាវដុំ និង ជាវរាយ

សៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ "បណ្ណាគារត្រៃរតន៍"

#136E0 វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខ: 012 706 581

097 905 00 55

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។